# ធម្មបទ ៤២៣ គាថា



ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

រៀបរៀងជាក់លេខទំព័រគ្រប់គាថា

ដោយ ហួយ រ៉ាន់ថន និង ស៊ិន សុផាន

ពុទ្ធសករាជ ២៥៦៣

# ធម្មបទគាថា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

## ១. យមកវគ្គ

១.១[*] មនោបុព្ពង្គមា ធម្មា, មនោសេដ្ឋា មនោមយា;
មនសា ចេ បទុដ្ឋេន, ភាសតិ វា ករោតិ វា;
តតោ នំ ទុក្ខមន្វេតិ, ចក្កំវ វហតោ បទំ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី(នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ។

(បិ. ៥២ ទំ. ២១)

២.២ មនោបុព្ពង្គមា ធម្មា, មនោសេដ្ឋា មនោមយា;
មនសា ចេ បសន្នេន, ភាសតិ វា ករោតិ វា;
តតោ នំ សុខមន្វេតិ, ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ។

(បិ. ៥២ ទំ. ២១)

៣.៣ អក្កោច្ឆិ មំ អវធិ មំ, អជិនិ មំ អហាសិ មេ;
យេ ច តំ ឧបនយ្ហន្តិ, វេរំ តេសំ ន សម្មតិ។

---

[*] លេខដំបូង ជាលេខរៀងតាមលំដាប់គាថាទាំងអស់ ពីគាថាទី១រហូតដល់ គាថាទី៤២៣, លេខបន្ទាប់ ជាលេខរៀងក្នុងវគ្គនីមួយៗ ។

អ្នកឯណោះបានជេរអញ អ្នកឯណោះបានវាយអញ អ្នកឯណោះបានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា ចងសេចក្តីក្រោធបែបនោះទុក (ដូច្នេះ) ពៀររបស់អ្នកនោះមិនរម្ងាប់ឡើយ។

(បិ. ៥២ ទំ. ២១)

៤.៤ អក្កោច្ឆិ មំ អវធិ មំ, អជិនិ មំ អហាសិ មេ;
យេ ច តំ នុបនយ្ហន្តិ, វេរំ តេសូបសម្មតិ។

អ្នកឯណោះបានជេរអញ អ្នកឯណោះបានវាយអញ អ្នកឯណោះបានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកឯណាមិនចងសេចក្តីក្រោធ បែបនោះទុក(ដូច្នេះ) ពៀររបស់អ្នកនោះទើបរម្ងាប់បាន។

(បិ. ៥២ ទំ. ២១-២២)

៥.៥ ន ហិ វេរេន វេរានិ, សម្មន្តីធ កុទាចនំ;
អវេរេន ច សម្មន្តិ, ឯស ធម្មោ សនន្តនោ។

ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយមិនរម្ងាប់ដោយពៀរឡើយ ពៀរទាំងឡាយតែងរម្ងាប់ដោយមិនមានពៀរ នេះជាបវេណីធម៌។

(បិ. ៥២ ទំ. ២២)

៦.៦ បរេ ច ន វិជានន្តិ, មយមេត្ថ យមាមសេ;
យេ ច តត្ថ វិជានន្តិ, តតោ សម្មន្តិ មេធគា។

ជនទាំងឡាយដទៃ(ក្រៅអំពីបណ្ឌិត)តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូន្នេះហើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ។

(បិ. ៥២ ទំ. ២២)

៧.៧ សុភានុបស្សឹ វិហរន្តំ, ឥន្ទ្រិយេសុ អសំវុតំ;

ភោជនម្ហិ អមត្តញ្ញុំ, កុសីតំ ហីនវីរិយំ;

តំ វេ បសហតិ មារោ, វាតោ រុក្ខំវ ទុព្ពលំ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមាររមែងគ្របសង្កត់ បុគ្គលនោះឯង ដូចខ្យល់ដែលគ្រប់សង្កត់ដើមឈើទុព្វលដូច្នោះ។

(បិ. ៥២ ទំ. ២២)

៨.៨ អសុភានុបស្សឹ វិហរន្តំ, ឥន្ទ្រិយេសុ សុសំវុតំ;

ភោជនម្ហិ ច មត្តញ្ញុំ, សទ្ធំ អារទ្ធវីរិយំ;

តំ វេ នប្បសហតិ មារោ, វាតោ សេលំវ បព្វតំ។

ឯបុគ្គល ដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារតែងគ្រប់សង្កត់ បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ថ្មភ្នំតាន់មិនបានដូច្នោះ។

(បិ. ៥២ ទំ. ២២)

៩.៩ អនិក្កសាវោ កាសាវំ, យោ វត្ថំ បរិទហិស្សតិ;

អបេតោ ទមសច្ចេន, ន សោ កាសាវមរហតិ។

អ្នកណា នៅមានទឹកចត់គឺរាគាទិក្កិលេស(ក្នុងសន្តាន)ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយនិងសច្ចៈ ហើយស្លៀកដណ្តបសំពត់កាសាវៈ អ្នកនោះមិនគួរនឹងស្លៀកដណ្តប់សំពតកាសាវៈឡើយ។

(បិ. ៥២ ទំ. ២៣)

១០.១០ យោ ច វន្តកសាវស្ស, សីលេសុ សុសមាហិតោ;

ឧបេតោ ទមសច្ចេន, ស វេ កាសាវមរហតិ។

លុះតែអ្នកណា មានទឹកចត់គឺរាគាទិក្កិលេស ខ្ជាកចោលអស់ហើយ ជាអ្នកមានចិត្ត ដម្កល់មាំ ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយនិងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន។

(បិ. ៥២ ទំ. ២៣)

១១.១១ អសារេ សារមតិនោ, សារេ ចាសារទស្សិនោ;

តេ សារំ នាធិគច្ឆន្តិ, មិច្ឆាសង្កប្បគោចរា។

ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មានខ្លឹម ថាជាធម៌មិនមានខ្លឹមផងជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ។

(បិ. ៥២ ទំ. ២៣)

១២.១២ សារញ្ច សារតោ ញត្វា, អសារញ្ច អសារតោ;

តេ សារំ អធិគច្ឆន្តិ, សម្មាសង្កប្បគោចរា។

ជនទាំងឡាយ ដែលយល់ឃើញនូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញនូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម។

(បិ. ៥២ ទំ. ២៣)

១៣.១៣ យថា អគារំ ទុច្ឆន្នំ, វុដ្ឋី សមតិវិជ្ឈតិ;

ឯវំ អភាវិតំ ចិត្តំ, រាគោ សមតិវិជ្ឈតិ។

ផ្ទះដែលប្រក់ខ្ចីខ្ចាហើយ ដំណក់ទឹកភ្លៀងរមែងលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោតយ៉ាងនោះឯង។

(បិ. ៥២ ទំ. ២៣)

១៤.១៤ យថា អគារំ សុច្ឆន្នំ, វុដ្ឋី ន សមតិវិជ្ឈតិ;

ឯវំ សុភាវិតំ ចិត្តំ, រាគោ ន សមតិវិជ្ឈតិ។

ផ្ទះដែលប្រក់ល្អហើយ ដំណក់ទឹកភ្លៀងរមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង។

(បិ. ៥២ ទំ. ២៤)

១៥.១៥ ឥធ សោចតិ បេច្ច សោចតិ, បាបការី ឧភយត្ថ សោចតិ;

សោ សោចតិ សោ វិហញ្ញតិ, ទិស្វា កម្មកិលិដ្ឋមត្តនោ។

បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយក្នុងលោកនេះ១ ក្នុងលោកខាមុខ១ បុគ្គលនោះ រមែងសោកស្តាយ ក្តៅក្រហាយព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន។

(បិ. ៥២ ទំ. ២៤)

១៦.១៦ ឥធ មោទតិ បេច្ច មោទតិ, កតបុញ្ញោ ឧភយត្ថ មោទតិ;

សោ មោទតិ សោ បមោទតិ, ទិស្វា កម្មវិសុទ្ធិមត្តនោ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ១ រីករាយក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន។

(បិ. ៥២ ទំ. ២៤)

១៧.១៧ ឥធ តប្បតិ បេច្ច តប្បតិ, បាបការី ឧភយត្ថ តប្បតិ;

"បាបំ មេ កត"ន្តិ តប្បតិ, ភិយ្យោ តប្បតិ ទុគ្គតឹ គតោ។

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ១ ក្តៅក្រហាយក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង។

(បិ. ៥២ ទំ. ២៤)

១៨.១៨ ឥធ នន្ទតិ បេច្ច នន្ទតិ, កតបុញ្ញោ ឧភយត្ថ នន្ទតិ;
"បុញ្ញំ មេ កត"ន្តិ នន្ទតិ, ភិយ្យោ នន្ទតិ សុគ្គតឹ គតោ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរ ក្នុងលោកទាំងពីរគឺត្រេកអរក្នុងលោកនេះ១ ត្រេកអរក្នុងលោកខាងមុខ១ បុគ្គលនោះរមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង។

(បិ. ៥២ ទំ. ២៥)

១៩.១៩ ពហុម្បិ ចេ សំហិត ភាសមានោ, ន តក្ករោ ហោតិ នរោ បមត្តោ;
គោបោវ គាវោ គណយំ បរេសំ, ន ភាគវា សាមញ្ញស្ស ហោតិ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីច្រើន តែជាអ្នកប្រមាទមិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ(ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស)ដូច្នោះឯង។

(បិ. ៥២ ទំ. ២៥)

២០.២០ អប្បម្បិ ចេ សំហិត ភាសមានោ, ធម្មស្ស ហោតិ អនុធម្មចារី;
រាគញ្ច ទោសញ្ច បហាយ មោហំ, សម្មប្បជានោ សុវិមុត្តចិត្តោ;
អនុបាទិយានោ ឥធ វា ហុរំ វា, ស ភាគវា សាមញ្ញស្ស ហោតិ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈទោសៈនិងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្ដីសៅហ្មង មិនមានសេចក្ដីប្រកាន់មាំ ក្នុងលោកនេះនិងលោកខាងមុខ នរជននោះ រមែងជាអ្នកបានចំណែកសាមញ្ញផល។

(បិ. ៥២ ទំ. ២៥)

ចប់យមកវគ្គ។

## ២. អប្បមាទវគ្គ

២១.១ អប្បមាទោ អមតំបទំ, បមាទោ មច្ចុនោ បទំ;
អប្បមត្តា ន មីយន្តិ, យេ បមត្តា យថា មតា។

សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ។

(បិ. ៥២ ទំ. ២៥)

២២.២ ឯតំ វិសេសតោ ញត្វា, អប្បមាទម្ហិ បណ្ឌិតា;
អប្បមាទេ បមោទន្តិ, អរិយានំ គោចរេ រតា។

ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះដោយប្លែកគ្នា(ទើបឋិតនៅ)ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាគោចរ ។

(បិ. ៥២ ទំ. ២៥-២៦)

២៣.៣ តេ ឈាយិនោ សាតតិកា, និច្ចំ ទឡ្ហបរក្កមា;
ផុសន្តិ ធីរា និព្ពានំ, យោគក្ខេមំ អនុត្តរំ។

អរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញាតែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតិដ៏ប្រសើរបំផុត។

(បិ. ៥២ ទំ. ២៦)

២៤.៤ ឧដ្ឋានវតោ សតីមតោ , សុចិកម្មស្ស និសម្មការិនោ;
សញ្ញតស្ស ច ធម្មជីវិនោ, អប្បមត្តស្ស យសោភិវឌ្ឍតិ។

យសតែងចំរើនកុះករ ដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត(ឥតទោស) ជាអ្នកពិចារណា រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌មិនមានសេចក្តីប្រមាទ។

(បិ. ៥២ ទំ. ២៦)

២៥.៥ ឧដ្ឋានេនប្បមាទេន, សញ្ញមេន ទមេន ច;
ទីបំ កយិរាថ មេធាវី, យំ ឱឃោ នាភិកីរតិ។

អ្នកប្រាជ្ញគប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់គឺកិលេសជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយសេចក្តីសង្រួមផង ដោយសេចក្តីសង្រួមក្នុងចតុប្បារិសុទ្ធិសីលផល ដោយការទូន្មានឥន្ទ្រិយផង។

(បិ. ៥២ ទំ. ២៦)

២៦.៦ បមាទមនុយុញ្ជន្តិ, ពាលា ទុម្មេធិនោ ជនា;
អប្បមាទញ្ច មេធាវី, ធនំ សេដ្ឋំវ រក្ខតិ។

ពួកពាលជនអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញរមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ។

(បិ. ៥២ ទំ. ២៦)

២៧.៧ មា បមាទមនុយុញ្ជេថ, មា កាមរតិសន្ថវំ;
អប្បមត្តោ ហិ ឈាយន្តោ, បប្បោតិ វិបុលំ សុខំ។

អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗនូវសេចក្តីរីករាយ ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្តីសុខដ៏ទូលាយ។

(បិ. ៥២ ទំ. ២៦)

២៨.៨ បមាទំ អប្បមាទេន, យទា នុទតិ បណ្ឌិតោ;

បញ្ញាបាសាទមារុយ្ហ, អសោកោ សោកិនឹ បជំ;
បព្វតដ្ឋោវ ភុម្មដ្ឋេ, ធីរោ ពាលេ អវេក្ខតិ។

កាលណាបណ្ឌិតបន្ទោបង់នូវសេចក្ដីប្រមាទដោយសេចក្ដីមិនប្រមាទ កាលនោះ លោកនឹងឡើងកាន់ប្រាសាទគឺបញ្ញាជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែល មានសោក ធីរជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយ ក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង។

(បិ. ៥២ ទំ. ២៧)

២៩.៩ អប្បមត្តោ បមត្តេសុ, សុត្តេសុ ពហុជាគរោ;
អពលស្សំវ សីឃស្សោ, ហិត្វា យាតិ សុមេធសោ។

បណ្ឌិតមានប្រាជ្ញាមុះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿន ដែលទៅចោលនូវសេះមានកំលាំងទន់ទាប ដូច្នោះឯង។

(បិ. ៥២ ទំ. ២៧)

៣០.១០ អប្បមាទេន មឃវា, ទេវានំ សេដ្ឋតំ គតោ;
អប្បមាទំ បសំសន្តិ, បមាទោ គរហិតោ សទា។

មឃមានពដល់នូវភាពជាបុគ្គលប្រសើរបំផុតជាងទេវតាទាំងឡាយ ព្រោះតែសេចក្ដីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយតែងសរសើរនូវសេចក្ដីមិនប្រមាទ ត្មះតិះដៀលនូវសេចក្ដីប្រមាទសព្វៗកាល។

(បិ. ៥២ ទំ. ២៧)

៣១.១១ អប្បមាទរតោ ភិក្ខុ, បមាទេ ភយទស្សិ វា;
សំយោជនំ អណុំ ថូលំ, ឌហំ អគ្គីវ គច្ឆតិ។

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ តែងដុតចោលសំយោជនៈ ទាំងតូចទាំងធំ ដូចភ្លើងឆេះ(រាល់នូវកំទេចទាំងតូចទាំងធំ) ដូច្នោះឯង។

(បិ. ៥២ ទំ. ២៧)

៣២.១២ អប្បមាទរតោ ភិក្ខុ, បមាទេ ភយទស្សិ វា;
អភព្វោ បរិហានាយ, និព្វានស្សេវ សន្តិកេ។

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះព្រះនិព្វាន។

(បិ. ៥២ ទំ. ២៨)

## ចប់អប្បមាទវគ្គ។

## ៣. ចិត្តវគ្គ

៣៣.១ ផន្ទនំ ចបលំ ចិត្តំ, ទូរក្ខំ ទុន្និវារយំ;
ឧជុំ ករោតិ មេធាវី, ឧសុការោវ តេជនំ។

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បានដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់។

(បិ. ៥២ ទំ. ២៨)

៣៤.២ វារិជោវ ថលេ ខិត្តោ, ឱកមោកតឧព្ភតោ;
បរិផន្ទតិទំ ចិត្តំ, មារធេយ្យំ បហាតវេ។

ចិត្តនេះដែលបុគ្គលលើកឡើងចាកអាល័យ គឺកាមគុណ៥បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទីនៅគឺទឹក បោះទីលើគោក ដូច្នោះឯង។

(បិ. ៥២ ទំ. ២៨)

៣៥.៣ ទុន្និគ្គហស្ស លហុនោ, យត្ថកាមនិបាតិនោ;

ចិត្តស្ស ទមថោ សាធុ, ចិត្តំ ទន្តំ សុខាវហំ។

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតិរហ័យ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា)ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្ដីសុខ។

(បិ. ៥២ ទំ. ២៨)

៣៦.៤ សុទុទ្ទសំ សុនិបុណំ, យត្ថកាមនិបាតិនំ;

ចិត្តំ រក្ខេថ មេធាវី, ចិត្តំ គុត្តំ សុខាវហំ។

អ្នកមានប្រាជ្ញាគួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាប់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ(ព្រោះថា)ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ។

(បិ. ៥២ ទំ. ២៩)

៣៧.៥ ទូរង្គមំ ឯកចរំ, អសរីរំ គុហាសយំ;

យេ ចិត្តំ សញ្ញមេស្សន្តិ, មោក្ខន្តិ មារពន្ធនា។

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគូហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាក ចំណងនៃមារ។

(បិ. ៥២ ទំ. ២៩)

៣៨.៦ អនវដ្ឋិតចិត្តស្ស, សទ្ធម្មំ អវិជានតោ;

បរិប្លវបសាទស្ស, បញ្ញា ន បរិបូរតិ។

ប្រាជ្ញារមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្ដីជ្រះថ្លាអណ្ដែតទៅហើយ។

(បិ. ៥២ ទំ. ២៩)

៣៩.៧ អនវស្សុតចិត្តស្ស, អនន្វាហតចេតសោ;

បុញ្ញបាបបហីនស្ស, នត្ថិ ជាគរតោ ភយំ។

ភ័យរមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យនឹងបាបលះចោលហើយភ្ញាក់រឭកជានិច្ច។

(បិ. ៥២ ទំ. ២៩)

៤០.៨ **កុម្ភូបមំ កាយមិមំ វិទិត្វា, នគរូបមំ ចិត្តមិទំ ឋបេត្វា;**
**យោធេថ មារំ បញ្ញាវុធេន, ជិតញ្ច រក្ខេ អនិវេសនោ សិយា។**

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ(ក្នុងធម៌)ឡើយ។

(បិ. ៥២ ទំ. ៣០)

៤១.៩ **អចិរំ វតយំ កាយោ, បថវឹ អធិសេស្សតិ;**

**ឆុទ្ធោ អបេតវិញ្ញាណោ, និរត្ថំវ កលិង្គរំ។**

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅប្រាស គេយកទៅចោលផុតហើយ មុខជានឹងដេកស្តូកស្តឹងលើផែនដី ដូចជាអង្កត់ឱស រកប្រយោជន៍គ្មាន។

(បិ. ៥២ ទំ. ៣០)

៤២.១០ **ទិសោ ទិសំ យន្តំ កយិរា, វេរី វា បន វេរិនំ;**

**មិច្ឆាបណិហិតំ ចិត្តំ, ចាបិយោ នំ តតោ ករេ។**

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះឲ្យអាក្រក់ក្រៃលែង ជាងសេចក្តីវិនាសនោះទៅទៀត។

(បិ. ៥២ ទំ. ៣០)

៤៣.១១ **ន តំ មាតា បិតា កយិរា, អញ្ញេ វាបិ ច ញាតកា;**

**សម្មាបណិហិតំ ចិត្តំ, សេយ្យសោ នំ តតោ ករេ។**

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិមិនគប្បីធ្វើនូវ ហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន។

(បិ. ៥២ ទំ. ៣០)

## ចប់ចិត្តវគ្គ។

## ៤. បុប្ផវគ្គ

៤៤.១ កោ ឥមំ បឋវឹ វិជេស្សតិ , យមលោកញ្ច ឥមំ សទេវកំ;
កោ ធម្មបទំ សុទេសិតំ, កុសលោ បុប្ផមិវ បចេស្សតិ។

អ្នកណានឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ និងយមលោកគឺអបាយភូមិ ៤ និងមនុស្សលោកនេះព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសំដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះឯង។

(បិ. ៥២ ទំ. ៣០)

៤៥.២ សេខោ បឋវឹ វិចេស្សតិ, យមលោកញ្ច ឥមំ សទេវកំ;
សេខោ ធម្មបទំ សុទេសិតំ, កុសលោ បុប្ផមិវ បចេស្សតិ។

ព្រះសេក្ខបុគ្គលនឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ និងយមលោកគឺអបាយភូមិ៤និងមនុស្សលោកនេះព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គលនឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសំដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះ។

(បិ. ៥២ ទំ. ៣១)

៤៦.៣ ផេណូបមំ កាយមិមំ វិទិត្វា, មរីចិធម្មំ អភិសម្ពុធានោ;
ឆេត្វាន មារស្ស បបុប្ផកានិ , អទស្សនំ មច្ចុរាជស្ស គច្ឆេ។

ភិក្ខុនឹងដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចព្រេញថ្ងៃ គប្បីកាត់នូវផ្កាជាប្រធាននៃមារគឺវដ្ដៈ៣ទៅកាន់ស្ថានជាទីមិនឃើញនៃមច្ចុរាជ។

(បិ. ៥២ ទំ. ៣១)

៤៧.៤ បុប្ផានិ ហេវ បចិនន្តំ, ព្យាសត្តមនសំ នរំ;

សុត្តំ គាមំ មហោឃោវ, មច្ចុ អាទាយ គច្ឆតិ។

មច្ចុគឺសេចក្តីស្លាប់តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ ៥ នុះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង។

(បិ. ៥២ ទំ. ៣១)

៤៨.៥ បុប្ផានិ ហេវ បចិនន្តំ, ព្យាសត្តមនសំ នរំ;

អតិត្តំយេវ កាមេសុ, អន្តកោ កុរុតេ វសំ។

អ្នកធ្វើទីបំផុតគឺមរណៈ តែងក្រុងសត្វ ដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនុះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន។

(បិ. ៥២ ទំ. ៣១)

៤៩.៦ យថាបិ ភមរោ បុប្ផំ, វណ្ណគន្ធំ អហេឋយំ ;

បលេតិ រសមាទាយ, ឯវំ គាមេ មុនី ចរេ។

ភមរជាតិមិនធ្វើផ្កាឈើដែលមានពណ៌និងក្លិនឲ្យវិនាសទេ ក្រេបយកតែរស ហើរទៅយ៉ាងណាមិញ អ្នកប្រាជ្ញគប្បីត្រាច់ទៅក្នុងស្រុកក៏យ៉ាងនោះឯង។

(បិ. ៥២ ទំ. ៣១)

៥០.៧ ន បរេសំ វិលោមានិ, ន បរេសំ កតាកតំ;

អត្តនោវ អវេក្ខេយ្យ, កតានិ អកតានិ ច។

ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយនឹងមិនទាន់ធ្វើហើយរបស់ជនដទៃ(ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិ

ត្យមើលទេ បុគ្គលគួរពិនិត្យពិចារណា តែកិច្ចការទាំងឡាយ ដែលធ្វើហើយនឹងមិនទាន់ធ្វើហើយរបស់ខ្លួនតែម៉្យាង។

(បិ. ៥២ ទំ. ៣២)

៥១.៨ យថាបិ រុចិរំ បុប្ផំ, វណ្ណវន្តំ អគន្ធកំ;
ឯវំ សុភាសិតា វាចា, អផលា ហោតិ អកុព្ពតោ។

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌(ល្អ) តែគ្មានក្លិន(ក្រអូប)(រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់)ដូចម្តេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ។

(បិ. ៥២ ទំ. ៣២)

៥២.៩ យថាបិ រុចិរំ បុប្ផំ, វណ្ណវន្តំ សគន្ធកំ ;
ឯវំ សុភាសិតា វាចា, សផលា ហោតិ កុព្ពតោ ។

ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន(រមែងក្រអូបដល់អ្នកដែលទ្រទ្រង់)ដូចម្តេចមិញ វាចាជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង។

(បិ. ៥២ ទំ. ៣២)

៥៣.១០ យថាបិ បុប្ផរាសិម្ហា, កយិរា មាលាគុណេ ពហូ;
ឯវំ ជាតេន មច្ចេន, កត្តព្វំ កុសលំ ពហុំ។

មាលាការចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា(ផ្សេងៗគ្នា) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ។

(បិ. ៥២ ទំ. ៣២)

៥៤.១១ ន បុប្ផគន្ធោ បដិវាតមេតិ, ន ចន្ទនំ តគរមល្លិកាវា;
សតញ្ច គន្ធោ បដិវាតមេតិ, សព្វា ទិសា សប្បុរិសោ បវាយតិ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាស់ខ្យល់មិនបាន ក្លិនខ្លឹមច័ន្ទន៍ក្តី ក្លិមខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរសរមែងផ្សាយទៅគ្រប់ទិស។

(បិ. ៥២ ទំ. ៣២-៣៣)

៥៥.១២ ចន្ទនំ តគរំ វាបិ, ឧប្បលំ អថ វស្សិកី;
ឯតេសំ គន្ធជាតានំ, សីលគន្ធោ អនុត្តរោ។

ក្លិននៃសីលជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិទាំងនេះគឺ ខ្លឹមច័ន្ទន៍ ខ្លឹមប្រស្នា ផ្កាឧប្បល ផ្កាម្លិះលា។

(បិ. ៥២ ទំ. ៣៣)

៥៦.១៣ អប្បមត្តោ អយំ គន្ធោ, យ្វាយំ តគរចន្ទនំ ;
យោ ច សីលវតំ គន្ធោ, វាតិ ទេវេសុ ឧត្តមោ។

ក្លិនក្រស្នា និងក្លិនច័ន្ទន៍ណា ក្លិននេះក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះទើបក្រអូបលើសលប់ ផ្សាយទៅក្នុងទេវលោកនិងមនុស្សលោកបាន។

(បិ. ៥២ ទំ. ៣៣)

៥៧.១៤ តេសំ សម្បន្នសីលានំ, អប្បមាទវិហារិនំ;
សម្មទញ្ញា វិមុត្តានំ, មារោ មគ្គំ ន វិន្ទតិ។

មារាធិរាជ(ទុកជាខំស្វែងរក)ក៏មិនជួបនូវផ្លូវរបស់លោក អ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ(ចាកធមិជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់នូវហេតុ។

(បិ. ៥២ ទំ. ៣៣)

៥៨.១៥ យថា សង្ការធានស្មឹ , ឧជ្ឈិតស្មឹ មហាបថេ;
បទុមំ តត្ថ ជាយេថ, សុចិគន្ធំ មនោរមំ។

ផ្កាឈូកទុកជាកើតក្នុងគំនរសម្រាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្ដេចមិញ ។

(បិ. ៥២ ទំ. ៣៣)

៥៩.១៦ ឯវំ សង្ការភូតេសុ, អន្ធភូតេ បុថុជ្ជនេ;

អតិរោចតិ បញ្ញាយ, សម្មាសម្ពុទ្ធសាវកោ។

បណ្ដាជនដែលដូចជាគំនរសម្រាម សាវ័ករបស់ព្រះសម្មាសម្ពុទ្ធរមែងរុងរឿងកន្លងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ ដោយប្រាជ្ញា(របស់ខ្លួន) ដូច្នោះឯង។

(បិ. ៥២ ទំ. ៣៣)

ចប់បុប្ផវគ្គ។

## ៥. ពាលវគ្គ

៦០.១ ទីឃា ជាគរតោ រត្តិ, ទីឃំ សន្តស្ស យោជនំ;

ទីឃោ ពាលានំ សំសារោ, សទ្ធម្មំ អវិជានតំ។

រាត្រីវែងចំពោះតែអ្នកភ្ញាក់រឭក(អ្នកដែលមិនលក់)យោជន៍វែងចំពោះតែអ្នកនឿយហត់ សង្សារវដ្ដវែងចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម។

(បិ. ៥២ ទំ. ៣៤)

៦១.២ ចរញ្ចេ នាធិគច្ឆេយ្យ, សេយ្យំ សទិសមត្តនោ;

ឯកចរិយំ ទឡ្ហំ កយិរា, នត្ថិ ពាលេ សហាយតា។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួនឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯងឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថាសហា យតាគុណមិនមានក្នុងបុគ្គលពាលឡើយ។

(បិ. ៥២ ទំ. ៣៤)

៦២.៣ បុត្តា មត្ថិ ធនមត្ថិ, ឥតិ ពាលោ វិហញ្ញតិ;

អត្ថា ហិ អត្តនោ នត្ថិ, កុតោ បុត្តា កុតោ ធនំ។

ជនពាលតែងព្រួយលំបាកដោយសេចក្តីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិតសូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណាង់បើកូនទាំងឡាយនឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថាមានអំពីណាបាន។

(បិ. ៥២ ទំ. ៣៤)

៦៣.៤ យោ ពាលោ មញ្ញតិ ពាល្យំ, បណ្ឌិតោ វាបិ តេន សោ;

ពាលោ ច បណ្ឌិតមានី, ស វេ "ពាលោ"តិ វុច្ចតិ។

អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ ម្យ៉ាងទៀត អ្នកណាជាមនុស្សពាល មានសេចក្តីប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះឈ្មោះថាជាមនុស្សពាល ដោយពិត។

(បិ. ៥២ ទំ. ៣៤)

៦៤.៥ យាវជីវម្បិ ចេ ពាលោ, បណ្ឌិតំ បយិរុបាសតិ;

ន សោ ធម្មំ វិជានាតិ, ទព្វី សូបរសំ យថា។

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិតក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចវែកដែលមិនដឹងរសសម្ល។

(បិ. ៥២ ទំ. ៣៥)

៦៥.៦ មុហុត្តមបិ ចេ វិញ្ញូ, បណ្ឌិតំ បយិរុបាសតិ;

ខិប្បំ ធម្មំ វិជានាតិ, ជិវ្ហា សូបរសំ យថា។

វិញ្ញូជនបើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌ ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល។

(បិ. ៥២ ទំ. ៣៥)

៦៦.៧ ចរន្តិ ពាលា ទុម្មេធា, អមិត្តេនេវ អត្តនា;

ករោន្តា បាបកំ កម្មំ, យំ ហោតិ កដុកប្ផលំ។

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមកដែលជាអំពើមានផលក្តៅក្រហាយ។

(បិ. ៥២ ទំ. ៣៥)

៦៧.៨ **ន តំ កម្មំ កតំ សាធុ, យំ កត្វា អនុតប្បតិ;**

**យស្ស អស្សុមុខោ រោទំ, វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ។

(បិ. ៥២ ទំ. ៣៥)

៦៨.៩ **តញ្ច កម្មំ កតំ សាធុ, យំ កត្វា នានុតប្បតិ;**

**យស្ស បតីតោ សុមនោ, វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្តមានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ។

(បិ. ៥២ ទំ. ៣៥)

៦៩.១០ **មធុវា មញ្ញតិ ពាលោ, យាវ បាបំ ន បច្ចតិ;**

**យទា ច បច្ចតិ បាបំ, ពាលោ ទុក្ខំ និគច្ឆតិ។**

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសំគាល់នូវបាបនោះថាដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាលទើបប្រទះនូវសេចក្តីទុក្ខ ក្នុងកាលនោះ។

(បិ. ៥២ ទំ. ៣៥)

៧០.១១ **មាសេ មាសេ កុសគ្គេន, ពាលោ ភុញ្ជេថ ភោជនំ;**

**ន សោ សង្ខាតធម្មានំ, កលំ អគ្ឃតិ សោឡសឹ។**

ជនពាលទុកជាបរិភោគភោជនដោយចុងស្បូវរាល់ ៗ ខែ ជនពាលនោះក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ ៗ លើករបស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយឡើយ។

(បិ. ៥២ ទំ. ៣៦)

៧១.១២ ន ហិ បាបំ កតំ កម្មំ, សជ្ជុ ខីរំវ មុច្ចតិ;
ឌហន្តំ ពាលមន្វេតិ, ភស្មាឆន្នោវ បាវកោ។

កម្មលាមកដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយដូច្នោះ បាបកម្មនោះតាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះដូច្នោះ។

(បិ. ៥២ ទំ. ៣៦)

៧២.១៣ យាវទេវ អនត្ថាយ, ញត្តំ ពាលស្ស ជាយតិ;
ហន្តិ ពាលស្ស សុក្កំសំ, មុទ្ធំ អស្ស វិបាតយំ។

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញ៉ាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំណែកធម៌សគឺកុសលរបស់បុគ្គលពាលនោះ។

(បិ. ៥២ ទំ. ៣៦)

៧៣.១៤ អសន្តំ ភាវនមិច្ឆេយ្យ, បុរេក្ខារញ្ច ភិក្ខុសុ;
អាវាសេសុ ច ឥស្សរិយំ, បូជា បរកុលេសុ ច។

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមានក្នុងខ្លួនផងនូវការធ្វើក្នុងខាងមុខ គឺជាប្រមុខក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយក្នុងត្រកូលនៃជនទាំងឡាយដទៃផង។

(បិ. ៥២ ទំ. ៣៦)

៧៤.១៥ មមេវ កត មញ្ញន្តុ, គិហីបព្ពជិតា ឧភោ;
មមេវាតិវសា អស្សុ, កិច្ចាកិច្ចេសុ កិស្មិចិ;
ឥតិ ពាលស្ស សង្កប្បោ, ឥច្ឆា មានោ ច វឌ្ឍតិ។

ភិក្ខុពាល តែងមានសេចក្តីត្រិះរិះថា គ្រហស្ថនឹងបព្វជិត ទាំង ២ ពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូច ធំ ណា ៗ មួយ ឬស្សា នឹងមានះរមែងចំរើន។

(បិ. ៥២ ទំ. ៣៧)

៧៥.១៦ អញ្ញា ហិ លាភូបនិសា, អញ្ញា និព្វានគាមិនី;
ឯវមេតំ អភិញ្ញាយ, ភិក្ខុ ពុទ្ធស្ស សាវកោ;
សក្ការំ នាភិនន្ទេយ្យ, វិវេកមនុព្រូហយេ។

បដិបទា អាស្រ័យនូវលាភផ្សេង បដិបទាជាដំណើរទៅកាន់ព្រះព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនុះយ៉ាងនេះហើយ មិនគួរត្រេកអរ ចំពោះសក្ការៈឡើយ គប្បីញុំាងវិវេកឲ្យបំរើដោយលំដាប់។

(បិ. ៥២ ទំ. ៣៧)

## ចប់ពាលវគ្គ។

## ៦. បណ្ឌិតវគ្គ

៧៦.១ និធីនំវ បវត្តារំ, យំ បស្សេ វជ្ជទស្សិនំ;
និគ្គយ្ហវាទឹ មេធាវឹ, តាទិសំ បណ្ឌិតំ ភជេ;
តាទិសំ ភជមានស្ស, សេយ្យោ ហោតិ ន បាបិយោ។

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោសថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នេះ គួរគប់អ្នកប្រាជ្ញបែបនោះ(ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ។

(បិ. ៥២ ទំ. ៣៧)

៧៧.២ ឱវទេយ្យានុសាសេយ្យ, អសព្ភា ច និវារយេ;
សតំ ហិ សោ បិយោ ហោតិ, អសតំ ហោតិ អប្បិយោ។

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ។

(បិ. ៥២ ទំ. ៣៨)

៧៨.៣ ន ភជេ បាបកេ មិត្តេ, ន ភជេ បុរិសាធមេ;
ភជេថ មិត្តេ កល្យាណេ, ភជេថ បុរិសុត្តមេ។

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់។

(បិ. ៥២ ទំ. ៣៨)

៧៩.៤ ធម្មបីតិ សុខំ សេតិ, វិប្បសន្នេន ចេតសា;
អរិយប្បវេទិតេ ធម្មេ, សទា រមតិ បណ្ឌិតោ។

បណ្ឌិតដែលមានសេចក្តីឆ្អែកក្នុងធម៌ មានសេចក្តីជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះអរិយៈ ប្រកាសទុកហើយគ្រប់ពេល។

(បិ. ៥២ ទំ. ៣៨)

៨០.៥ ឧទកញ្ហិ នយន្តិ នេត្តិកា, ឧសុការា នមយន្តិ តេជនំ;
ទារុំ នមយន្តិ តច្ឆកា, អត្តានំ ទមយន្តិ បណ្ឌិតា។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួយ តែងពត់ព្រួញ(ឲ្យត្រង់)អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន(ដូច្នោះដែរ)។

(បិ. ៥២ ទំ. ៣៨)

៨១.៦ សេលោ យថា ឯកឃនោ, វាតេន ន សមីរតិ;
ឯវំ និន្ទាបសំសាសុ, ន សមិញ្ជន្តិ បណ្ឌិតា។

ភ្នំថ្មតាន់ មិនរំភើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយក៏មិនរំភើប ព្រោះពាក្យតិះដៀល នឹងពាក្យសរសើរ ដូច្នោះឯង។

(បិ. ៥២ ទំ. ៣៨)

៨២.៧ យថាបិ រហទោ គម្ភីរោ, វិប្បសន្នោ អនាវិលោ;

ឯវំ ធម្មានិ សុត្វាន, វិប្បសីទន្តិ បណ្ឌិតា។

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់សួន យ៉ាងនោះ។

(បិ. ៥២ ទំ. ៣៨)

៨៣.៨ សព្ពត្ថ វេ សប្បុរិសា ចជន្តិ,

ន កាមកាមា លបយន្តិ សន្តោ;

សុខេន ផុដ្ឋា អថ វា ទុខេន,

ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ។

ពួកសប្បុរសតែងលះ(ឆន្ទរាគ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់រមែងមិនរអែរអូរ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្តីសុខឬទុក្ខពាល់ត្រូវហើយ រមែងមិនសំដែងអាការឡើងចុះឡើយ។

(បិ. ៥២ ទំ. ៣៩)

៨៤.៩ ន អត្តហេតុ ន បរស្ស ហេតុ,

ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ;

ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ,

ស សីលវា បញ្ញវា ធម្មិកោ សិយា។

បណ្ឌិតមិនគួរធ្វើអាក្រក់ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកប ដោយធម៌។

(បិ. ៥២ ទំ. ៣៩)

៨៥.១០ **អប្បកា តេ មនុស្សេសុ, យេ ជនា បារគាមិនោ;**

**អថាយំ ឥតរា បជា, តីរមេវានុធាវតិ។**

បណ្ដាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយគឺព្រះព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះរមែងស្ទុះទៅកាន់ត្រើយ(គឺសក្កាយទិដ្ឋិ)

(បិ. ៥២ ទំ. ៣៩)

៨៦.១១ **យេ ច ខោ សម្មទក្ខាតេ, ធម្មេ ធម្មានុវត្តិនោ;**

**តេ ជនា បារមេស្សន្តិ, មច្ចុធេយ្យំ សុទុត្តរំ។**

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគតទ្រង់សំដែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះព្រះនិព្វាន។

(បិ. ៥២ ទំ. ៣៩)

៨៧.១២ **កណ្ហំ ធម្មំ វិប្បហាយ, សុក្កំ ភាវេថ បណ្ឌិតោ;**

**ឱកា អនោកមាគម្ម, វិវេកេ យត្ថ ទូរមំ។**

បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញុំាងធម៌សឲ្យចំរើន(ដោយវិធី)ចេញចាកអាល័យគឺកាមគុណ ហើយឈមទៅរកព្រះព្រះនិព្វាន ជាធម្មជាតិមិនមានអាល័យ។

(បិ. ៥២ ទំ. ៣៩-៤០)

៨៨.១៣ **តត្រាភិរតិមិច្ឆេយ្យ, ហិត្វា កាមេ អកិញ្ចនោ;**

**បរិយោទបេយ្យ អត្តានំ, ចិត្តក្លេសេហិ បណ្ឌិតោ។**

បណ្ឌិតគប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរ ក្នុងវិវេកដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញ៉ាំងខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត។

(បិ. ៥២ ទំ. ៩០)

៨៩.១៤ យេសំ សម្ពោធិយង្គេសុ, សម្មា ចិត្តំ សុភាវិតំ;
អាទានបដិនិស្សគ្គេ, អនុបាទាយ យេ រតា;
ខីណាសវា ជុតិមន្តោ, តេ លោកេ បរិនិព្វុតា។

ចិត្តដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយក្នុងអង្គនៃធម៌ ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬ បណ្ឌិតទាំងឡាយណាមិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវ សេចក្តីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះ ៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិព្រះនិព្វានក្នុងលោក។

(បិ. ៥២ ទំ. ៩០)

## ចប់ បណ្ឌិតវគ្គ។

## ៧. អរហន្តវគ្គ

៩០.១ គតទ្ធិនោ វិសោកស្ស, វិប្បមុត្តស្ស សព្ពធិ;
សព្ពគន្ថប្បហីនស្ស, បរិឡាហោ ន វិជ្ជតិ។

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោកអ្នកមានផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ទាំងពួងមានកិលេសជាគ្រឿងចាក់ស្រេះទាំងពួងលះបង់ហើយ។

(បិ. ៥២ ទំ. ៩០)

៩១.២ ឧយ្យុញ្ជន្តិ សតីមន្តោ, ន និកេតេ រមន្តិ តេ;
ហំសាវ បល្លលំ ហិត្វា, ឱកមោកំ ជហន្តិ តេ។

ព្រះខីណាស្រពទាំងឡាយមានស្មារតី រមែងខ្វលខ្វាយ រមែងត្រេកអរក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះនូវអាល័យទាំងអស់ ដូចហង្សលះបង់ភក់ហើរទៅ ដូច្នោះ។

(បិ. ៥២ ទំ. ៤១)

៩២.៣ យេសំ សន្និចយោ នត្ថិ, យេ បរិញ្ញាតភោជនា;
សុញ្ញតោ អនិមិត្តោ ច, វិមោក្ខោ យេស គោចរោ;
អាកាសេវ សកុន្តានំ, គតិ តេសំ ទុរន្នយា។

ពួកជនណា មិនមានសេចក្តីសន្សំ ពួកជនណា កំណត់ដឹងភោជនហើយ ជនណាមាន សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខនិងអប្បណិហិតវិមោក្ខជាគោចរ គតិគឺដំណើររបស់ពួកជននោះ ៗ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបព្ធដ៏អាកាស ដូច្នោះ។

(បិ. ៥២ ទំ. ៤១)

៩៣.៤ យស្សាសវា បរិក្ខីណា, អាហារេ ច អនិស្សិតោ;
សុញ្ញតោ អនិមិត្តោ ច, វិមោក្ខោ យស្ស គោចរោ;
អាកាសេវ សកុន្តានំ, បទំ តស្ស ទុរន្នយំ។

ជនណាអស់អាសវៈហើយ ទាំងមិនអាស្រ័យ(តណ្ហានិងទិដ្ឋិ)ក្នុងអាហារ ជនណាមាន សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខនិងអប្បណិហិតវិមោក្ខជាគោចរ ដំណើររបស់ជននោះ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបព្ធដ៏អាកាស ដូច្នោះ។

(បិ. ៥២ ទំ. ៤១)

៩៤.៥ យស្សិន្ទ្រិយានិ សមថង្គតានិ,
អស្សា យថា សារថិនា សុទន្តា;
បហីនមានស្ស អនាសវស្ស,
ទេវាបិ តស្ស បិហយន្តិ តាទិនោ។

ឥន្ទ្រិយទាំងឡាយរបស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះដែលនាយសារថីហ្វឹកហ្វឺនរាបហើយ សូម្បីទេវតានិងមនុស្សទាំងឡាយក៏ស្រឡាញ់អ្នកនោះឯងដែលមានមានៈលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹងមិនញាប់ញ័រ។

(បិ. ៥២ ទំ. ៤១)

៩៥.៦ បឋវិសមោ នោ វិរុជ្ឈតិ, ឥន្ទខិលុបមោ តាទិ សុព្ពតោ;
រហទោវ អបេតកទ្ទមោ, សំសារា ន ភវន្តិ តាទិនោ។

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លាដូចអន្លង់ប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន។

(បិ. ៥២ ទំ. ៤២)

៩៦.៧ សន្តំ តស្ស មនំ ហោតិ, សន្តា វាចា ច កម្ម ច;
សម្មទញ្ញា វិមុត្តស្ស, ឧបសន្តស្ស តាទិនោ។

ចិត្តស្ងប់ វាចាស្ងប់និងកាយកម្មស្ងប់ រមែងមានដល់លោកដែលដឹងដោយប្រពៃផុតស្រឡះ(ចាករាគាទិក្កិលេស)ជាអ្នកស្ងប់រម្ងាប់ ដូច្នោះ។

(បិ. ៥២ ទំ. ៤២)

៩៧.៨ អស្សទ្ធោ អកតញ្ញូ ច, សន្ធិច្ឆេទោ ច យោ នរោ;
ហតាវកាសោ វន្តាសោ, ស វេ ឧត្តមបោរិសោ។

នរជនណាមិនជឿអ្នកដទៃផង ស្គាល់ព្រះព្រះនិព្វានផង កាត់នូវគ្រឿងតគឺវដ្តៈផង មានឱកាសកំចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះជាឧត្តមបុរស។

(បិ. ៥២ ទំ. ៤២)

៩៨.៩ គាមេ វា យទិ វារញ្ញេ, និន្នេ វា យទិ វា ថលេ;
យត្ថ អរហន្តោ វិហរន្តិ, តំ ភូមិរាមណេយ្យកំ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិ គួរត្រេកអរ។

(បិ. ៥២ ទំ. ៤២)

៩៩.១០ **រមណីយានិ អរញ្ញានិ, យត្ថ ន រមតី ជនោ;**

**វីតរាគា រមេស្សន្តិ, ន តេ កាមគវេសិនោ។**

ជន(អ្នកស្វែងរកកាម)រមែងមិនត្រេកអរ ក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម។

(បិ. ៥២ ទំ. ៤៣)

ចប់អរហន្តវគ្គ។

## ៨. សហស្សវគ្គ

១០០.១ **សហស្សមបិ ចេ វាចា, អនត្ថបទសំហិតា;**

**ឯកំ អត្ថបទំ សេយ្យោ, យំ សុត្វា ឧបសម្មតិ។**

បើវាចា សូម្បី ១ ពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែ ១ បទ ក៏ ឈ្មោះថា ប្រសើរជាង។

(បិ. ៥២ ទំ. ៤៣)

១០១.២ **សហស្សមបិ ចេ គាថា, អនត្ថបទសញ្ហិតា;**

**ឯកំ គាថាបទំ សេយ្យោ, យំ សុត្វា ឧបសម្មតិ។**

បើគាថាសូម្បី ១ ពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែ ១ បទ ក៏ឈ្មោះថាប្រសើរជាង។

(បិ. ៥២ ទំ. ៤៣)

១០២.៣ យោ ច គាថា សតំ ភាសេ, អនត្ថបទសញ្ហិតា;
ឯកំ ធម្មបទំ សេយ្យោ, យំ សុត្វា ឧបសម្មតិ។

អ្នកណា គប្បីពោលគាថាមួយរយជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បានបទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង។

(បិ. ៥២ ទំ. ៤៣)

១០៣.៤ យោ សហស្សំ សហស្សេន, សង្គាមេ មានុសេ ជិនេ;
ឯកញ្ច ជេយ្យមត្តានំ , ស វេ សង្គាមជុត្តមោ។

អ្នកណាគប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់មួយពាន់ ។ ដង គឺ មួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ។

(បិ. ៥២ ទំ. ៤៤)

១០៤.៥ អត្តា ហវេ ជិតំ សេយ្យោ, យា ចាយំ ឥតរា បជា;
អត្តទន្តស្ស បោសស្ស, និច្ចំ សញ្ញតចារិនោ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ។

(បិ. ៥២ ទំ. ៤៤)

១០៥.៦ នេវ ទេវោ ន គន្ធព្វោ, ន មារោ សហ ព្រហ្មុនា;
ជិតំ អបជិតំ កយិរា, តថារូបស្ស ជន្តុនោ។

ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជំនះរបស់សត្វមានសភាពដូច្នោះឲ្យត្រឡប់ចាញ់វិញបានឡើយ។

(បិ. ៥២ ទំ. ៤៤)

១០៦.៧ មាសេ មាសេ សហស្សេន, យោ យជេថ សតំ សមំ;

ឯកញ្ច ភាវិតត្តានំ, មុហុត្តមបិ បូជយេ;
សាយេវ បូជនា សេយ្យោ, យញ្ចេ វស្សសតំ ហុតំ។

អ្នកណាបូជា(លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ខែ ៗ អស់រយ ១០០ ឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់អ្នកដែលបូជាអស់១០០ឆ្នាំនោះ ការបូជាអស់១០០ឆ្នាំ មិនប្រសើរឡើយ។

(បិ. ៥២ ទំ. ៥៤)

១០៧.៨ យោ ច វស្សសតំ ជន្តុ, អគ្គឹ បរិចរេ វនេ;
ឯកញ្ច ភាវិតត្តានំ, មុហុត្តមបិ បូជយេ;
សាយេវ បូជនា សេយ្យោ, យញ្ចេ វស្សសតំ ហុតំ។

ជនណាបម្រើភ្លើងក្នុងព្រៃអស់១០០ឆ្នាំ ចំណែកអ្នកណាបូជាលោកដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់១០០ឆ្នាំមិនប្រសើរឡើយ។

(បិ. ៥២ ទំ. ៥៤)

១០៨.៩ យំ កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ,
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ;
សព្ពម្បិ តំ ន ចតុភាគមេតិ,
អភិវាទនា ឧជ្ជុគតេសុ សេយ្យោ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងនោះឯង រមែងមិនដល់នូវចំណែកទី៤នៃការអភិវាទន៍ ចំពោះលោកទាំងឡាយដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង។

(បិ. ៥២ ទំ. ៥៥)

១០៩.១០ អភិវាទនសីលិស្ស, និច្ចំ វុឌ្ឍាបចាយិនោ

ចត្តារោ ធម្មា វឌ្ឍន្តិ, អាយុ វណ្ណោ សុខំ ពលំ។

ធម៌៤ប្រការគឺ អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១ រមែងចំរើនដល់អ្នកដែលមានសេចក្តីអោនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្តីកោតក្រែងដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជានិច្ច។

(បិ. ៥២ ទំ. ៤៥)

១១០.១១ យោ ច វស្សសតំ ជីវេ, ទុស្សីលោ អសមាហិតោ;

ឯកាហំ ជីវិតំ សេយ្យោ, សីលវន្តស្ស ឈាយិនោ។

បុគ្គលណារស់នៅ១០០ឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានដម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីលមានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង។

(បិ. ៥២ ទំ. ៤៥)

១១១.១២ យោ ច វស្សសតំ ជីវេ, ទុប្បញ្ញោ អសមាហិតោ;

ឯកាហំ ជីវិតំ សេយ្យោ, បញ្ញវន្តស្ស ឈាយិនោ។

បុគ្គលណា រស់នៅ១០០ឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានកម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃរបស់លោកដែលមានប្រាជ្ញាមានការពិនិត្យពិចារណាជាប្រក្រតីប្រសើរជាង។

(បិ. ៥២ ទំ. ៤៥)

១១២.១៣ យោ ច វស្សសតំ ជីវេ, កុសីតោ ហីនវីរិយោ;

ឯកាហំ ជីវិតំ សេយ្យោ, វីរិយំ អារភតោ ទឡ្ហំ។

បុគ្គលណារស់នៅ១០០ឆ្នាំ ជាមនុស្សមានចិត្តងុលងុប ក្នុងអកុសលវិតក្កៈ មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃរបស់លោកដែលប្រារព្ធសេចក្តីព្យាយាមមាំមួនប្រសើរជាង។

(បិ. ៥២ ទំ. ៤៥)

១១៣.១៤ យោ ច វស្សសតំ ជីវេ, អបស្សំ ឧទយព្វយំ;

ឯកាហំ ជីវិតំ សេយ្យោ, បស្សតោ ឧទយព្វយំ។

បុគ្គលណារស់នៅ១០០ឆ្នាំ ឃើញការកើតឡើងនិងការវិនាសទៅ ការរស់នៅ សូម្បីតែមួយថ្ងៃរបស់លោកដែលឃើញការកើតឡើងនិងការវិនាសទៅ ប្រសើរជាង។

(បិ. ៥២ ទំ. ៨៦)

១១៤.១៥ យោ ច វស្សសតំ ជីវេ, អបស្សំ អមតំ បទំ;

ឯកាហំ ជីវិតំ សេយ្យោ, បស្សតោ អមតំ បទំ។

បុគ្គលណារស់នៅ១០០ឆ្នាំ មិនឃើញផ្លូវព្រះព្រះនិព្វាន ការរស់នៅសូម្បីតែមួយថ្ងៃរបស់លោកអ្នកឃើញផ្លូវព្រះព្រះនិព្វាន ប្រសើរជាង។

(បិ. ៥២ ទំ. ៨៦)

១១៥.១៦ យោ ច វស្សសតំ ជីវេ, អបស្សំ ធម្មមុត្តមំ;

ឯកាហំ ជីវិតំ សេយ្យោ, បស្សតោ ធម្មមុត្តមំ។

បុគ្គលណារស់នៅ១០០ឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង។

(បិ. ៥២ ទំ. ៨៦)

ចប់សហស្សវគ្គ។

## ៩. បាបវគ្គ

១១៦.១ អភិត្ថរេថ កល្យាណេ, បាបា ចិត្តំ និវារយេ;

ទន្ធំ ហិ ករោតោ បុញ្ញំ, បាបស្មឹ រមតី មនោ។

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថាកាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប។

(បិ. ៥២ ទំ. ៨៦)

១១៧.២ បាបញ្ចេ បុរិសោ កយិរា, ន នំ កយិរា បុនប្បុនំ;

ន តម្ហិ ឆន្ទំ កយិរាថ, ទុក្ខោ បាបស្ស ឧច្ចយោ។

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗឡើយ កុំគប្បីធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឲ្យ។

(បិ. ៥២ ទំ. ៤៦)

១១៨.៣ បុញ្ញញ្ចេ បុរិសោ កយិរា, កយិរាថេនំ បុនប្បុនំ;
តម្ហិ ឆន្ទំ កយិរាថ, សុខោ បុញ្ញស្ស ឧច្ចយោ។

បើបុគ្គលធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ ការសន្សំបុណ្យតែងនាំសេចក្តីសុខមកឲ្យ។

(បិ. ៥២ ទំ. ៤៧)

១១៩.៤ បាបោបិ បស្សតិ ភទ្រំ, យាវ បាបំ ន បច្ចតិ;
យទា ច បច្ចតិ បាបំ, អថ បាបោ បាបានិ បស្សតិ។

បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សបាបក៏នៅឃើញតែសេចក្តីចំរើនត្រឹមណោះ លុះកាលណា បាបឲ្យផល មនុស្សបាបទើបឃើញបាប ក្នុងកាលនោះ។

(បិ. ៥២ ទំ. ៤៧)

១២០.៥ ភទ្រោបិ បស្សតិ បាបំ, យាវ ភទ្រំ ន បច្ចតិ;
យទា ច បច្ចតិ ភទ្រំ, អថ ភទ្រោ ភទ្រានិ បស្សតិ។

អំពើល្អមិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អទើបឃើញល្អក្នុងកាលនោះ។

(បិ. ៥២ ទំ. ៤៧)

១២១.៦ មាវមញ្ញេថ បាបស្ស, ន មន្តំ អាគមិស្សតិ;
ឧទពិន្ទុនិបាតេន, ឧទកុម្ភោបិ បូរតិ;
អាបូរតិ ពាលោ បាបស្ស, ថោកំ ថោកំបិ អាចិនំ។

បុគ្គលមិនគួរមើលងាយបាបថាមានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹករមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាល កាលសន្សំបាបសូម្បីបន្តិចម្តងៗ គង់ពេញដោយបាប យ៉ាងនោះដែរ។

(បិ. ៥២ ទំ. ៤៧)

១២២.៧ មាវមញ្ញេថ បុញ្ញស្ស, ន មន្តំ អាគមិស្សតិ;
ឧទពិន្ទុនិបាតេន, ឧទកុម្ភោបិ បូរតិ;
អបូរតិ ធីរោ បុញ្ញស្ស, ថោកំ ថោកំ បិ អាចិនំ។

បុគ្គល មិនគួរមើលងាយបុណ្យថាមានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយបុណ្យយ៉ាងនោះ។

(បិ. ៥២ ទំ. ៤៧)

១២៣.៨ វាណិជោវ ភយំ មគ្គំ, អប្បសត្ថោ មហទ្ធនោ;
វិសំ ជីវិតុកាមោវ, បាបានិ បរិវជ្ជយេ។

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុគ្គលប្រាថ្នារស់នៅ ចៀសវាងថ្នាំពិសដូច្នោះដែរ។

(បិ. ៥២ ទំ. ៤៨)

១២៤.៩ បាណិម្ហិ ចេ វណោ នាស្ស, ហរេយ្យ បាណិនា វិសំ;
នាព្ពណំ វិសមន្វេតិ, នត្ថិ បាបំ អកុព្ពតោ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាបរមែងមិនមានដល់បុគ្គលអ្នកមិនធ្វើយ៉ាងនោះឯង។

(បិ. ៥២ ទំ. ៤៨)

១២៥.១០ យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ,
សុទ្ធស្ស បោសស្ស អនង្គណស្ស;
តមេវ ពាលំ បច្ចេតិ បាបំ,
សុខុមោ រជោ បដិវាតំវ ខិត្តោ។

បុគ្គលណាប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាបរមែងត្រឡប់មករកបុគ្គលពាលនោះវិញដូចធូលីល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់។

(បិ. ៥២ ទំ. ៥៨)

១២៦.១១ គព្ភមេកេ ឧប្បជ្ជន្តិ, និរយំ បាបកម្មិនោ;
សគ្គំ សុគតិនោ យន្តិ, បរិនិព្ពន្តិ អនាសវា។

ជនពួកខ្លះ កើតក្នុងគតិមនុស្ស ពួកអ្នកមានអំពើអាក្រក់ទៅកាន់នរក ពួកអ្នកមានគតិល្អទៅកាន់ឋានសួគ៌ ពួកអ្នកមិនមានអាសវៈបរិនិព្វាន។

(បិ. ៥២ ទំ. ៥៨)

១២៧.១២ ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ, ន បព្ពតានំ វិវរំ បវិសំ ;
ន វិជ្ជតី សោ ជគតិប្បទេសោ, យត្ថដ្ឋិតោ មុច្ចេយ្យ បាបកម្មា។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាបបាបកម្មបាន ទោះមិនដែលមានឡើយ។

(បិ. ៥២ ទំ. ៥៨)

១២៨.១៣ ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ, ន បព្ពតានំ វិវរំ បវិស្ស;
ន វិជ្ជតី សោ ជគតិប្បទេសោ, យត្ថដ្ឋិតំ នប្បសហេយ្យ មច្ចុ។

បុគ្គលទៅឮដ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាក សេចក្ដីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ សេចក្ដីស្លាប់គ្របសង្កត់ មិនបាននោះ មិនដែលមានឡើយ។

(បិ. ៥២ ទំ. ៥៩)

ចប់បាបវគ្គ។

## ១០. ទណ្ឌវគ្គ

១២៩.១ សព្ពេ តសន្តិ ទណ្ឌស្ស, សព្ពេ ភាយន្តិ មច្ចុនោ;
អត្តានំ ឧបមំ កត្វា, ន ហនេយ្យ ន ឃាតយេ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងខ្លាចចំពោះ សេចក្ដីស្លាប់គ្រប់ៗរូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរ ប្រើ គេឲ្យប្រហារឡើយ។

(បិ. ៥២ ទំ. ៥៩)

១៣០.២ សព្ពេ តសន្តិ ទណ្ឌស្ស, សព្ពេសំ ជីវិតំ បិយំ;
អត្តានំ ឧបមំ កត្វា, ន ហនេយ្យ ន ឃាតយេ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា)ជីវិតជាទីស្រឡាញ់របស់ សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេ ប្រហារឡើយ។

(បិ. ៥២ ទំ. ៥៩)

១៣១.៣ សុខកាមានិ ភូតានិ, យោ ទណ្ឌេន វិហឹសតិ;
អត្តនោ សុខមេសានោ, បេច្ច សោ ន លភតេ សុខំ។

ជនណាស្វែងរកសេចក្ដីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នា សេចក្ដីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្ដីសុខឡើយ។

(បិ. ៥២ ទំ. ៥៩)

១៣២.៤ សុខកាមានិ ភូតានិ, យោ ទណ្ឌេន ន ហឹសតិ;

អត្តនោ សុខមេសានោ, បេច្ច សោ លភតេ សុខំ។

ជនណាស្វែងរកសេចក្ដីសុខដើម្បីខ្លួន មិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្ដីសុខដោយអាជ្ញា ជននោះលះលោកនេះទៅហើយ រមែងបានសេចក្ដីសុខ។

(បិ. ៥២ ទំ. ៥០)

១៣៣.៥ មាវោច ផរុសំ កញ្ចិ, វុត្តា បដិវទេយ្យុ តំ;

ទុក្ខា ហិ សារម្ភកថា, បដិទណ្ឌា ផុសេយ្យុ តំ។

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្ដីថាឲ្យហើយ គេគប្បីស្ដីថាតបមកអ្នកវិញ ព្រោះថាការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើត ទុក្ខ ការតស៊ូទាំងឡាយគប្បីប៉ះពាល់នូវអ្នក។

(បិ. ៥២ ទំ. ៥០)

១៣៤.៦ សចេ នេរេសិ អត្តានំ, កំសោ ឧបហតោ យថា;

ឯស បត្តោសិ និព្ពានំ, សារម្ភោ តេ ន វិជ្ជតិ។

បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រដូចរគាំងដែលចៀរមាត់ចេញហើយ(រមែងមិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះព្រះនិព្វាន ការប្រណាំងប្រជែងមិនមានដល់អ្នក។

(បិ. ៥២ ទំ. ៥០)

១៣៥.៧ យថា ទណ្ឌេន គោបាលោ, គាវោ បាជេតិ គោចរំ;

ឯវំ ជរា ច មច្ចុ ច, អាយុំ បាជេន្តិ បាណិនំ។

គង្វាលគោរមែងកៀងគោទៅកាន់ទីគោចរដោយអាជ្ញា ដូចម្ដេចមិញ ជរានិងមច្ចុតែងកៀងអាយុរបស់សត្វទាំងឡាយដូច្នោះឯង។

(បិ. ៥២ ទំ. ៥០)

១៣៦.៨ អថ បាបានិ កម្មានិ, ករំ ពាលោ ន ពុជ្ឈតិ;

សេហិ កម្មេហិ ទុម្មេធោ, អគ្គិទឌ្ឍោវ តប្បតិ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅ ក្រហាយ ដោយសារកម្មរបស់ខ្លួនដូចត្រូវភ្លើងឆេះ។

(បិ. ៥២ ទំ. ៥០)

១៣៧.៩ យោ ទណ្ឌេន អទណ្ឌេសុ, អប្បទុដ្ឋេសុ ទុស្សតិ;

ទសន្នមញ្ញតរំ ឋានំ, ខិប្បមេវ និគច្ឆតិ។

១៣៨.១០ វេទនំ ផរុសំ ជានិំ, សរីរស្ស វ ភេទនំ ;

គរុកំ វាបិ អាពាធំ, ចិត្តក្ខេបំ វ បាបុណេ។

១៣៩.១១ រាជតោ វា ឧបសគ្គំ , អព្ភក្ខានំ វ ទារុណំ;

បរិក្ខយំ វ ញាតីនំ, ភោគានំ វ បភង្គុណំ។

១៤០.១២ អថ វស្ស អគារានិ, អគ្គិ ឌហតិ បាវកោ;

កាយស្ស ភេទា ទុប្បញ្ញោ, និរយំ សោ ឧបបជ្ជតិ ។

បុគ្គលណាប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ ណាមួយក្នុងហេតុ១០យ៉ាងដោយទាន់ហន់ គឺ គប្បីដល់ នូវវេទនាដ៏អាក្រក់១ សេចក្តីវិនាសទ្រព្យ១ បែកធ្លាយសរីរៈ១ អាពាធជាទម្ងន់១ ក្រឡកចិត្ត(ឆ្កួត)១ រឹបជាន់អំពីស្តេច១ ពោលពាក្យបង្កាប់ដ៏អាក្រក់១ អស់ពួកញាតិរលីង១ ពុក ផុយភោគសម្បត្តិទាំងឡាយ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ១ បុគ្គលមិន មានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងកើតក្នុងនរក។

(បិ. ៥២ ទំ. ៥១)

១៤១.១៣ ន នគ្គចរិយា ន ជដា ន បង្កា,

នានាសកា ថណ្ឌិលសាយិកា វា;

រជោជល្លំ ឧក្កុដិកប្បធានំ,

សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ។

ការប្រព្រឹត្តិអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធុលី ព្យាយាមអង្គុយប្រហោង មិនជម្រះសត្វដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ។

(បិ. ៥២ ទំ. ៥១)

១៤២.១៤ អលង្កតោ ចេបិ សមំ ចរេយ្យ,

សន្តោ ទន្តោ និយតោ ព្រហ្មចារី;

សព្ពេសុ ភូតេសុ និធាយ ទណ្ឌំ,

សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ។

បើបុគ្គលណាមានខ្លួនប្រដាប់ស្អិតស្អាងហើយ(ដោយគ្រឿងអម្ពរ) តែគប្បីប្រព្រឹត្តិស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន(ឥន្ទ្រិយ)ជាបុគ្គលទៀង(ចំពោះមគ្គផល)អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវ អាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះហៅថាព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថា ភិក្ខុក៏បាន។

(បិ. ៥២ ទំ. ៥១)

១៤៣.១៥ ហិរីនិសេធោ បុរិសោ, កោចិ លោកស្មិ វិជ្ជតិ;

យោ និទ្ទំ អបពោធេតិ , អស្សោ ភទ្រោ កសាមិវ។

បុរសអ្នកកំចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្តីខ្មាស់បាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះរកបានដោយក្រក្នុងលោក។

(បិ. ៥២ ទំ. ៥២)

១៤៤.១៦ អស្សោ យថា ភទ្រោ កសានិវិដ្ឋោ,

អាតាបិនោ សំវេគិនោ ភវាថ;

**សទ្ធាយ សីលេន ច វីរិយេន ច,**

**សមាធិនា ធម្មវិនិច្ឆយេន ច;**

**សម្បន្នវិជ្ជាចរណា បតិស្សតា,**

**ជហិស្សថ ទុក្ខមិទំ អនប្បកំ។**

សេះល្អដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្តីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិន័យផង ជាអ្នកមានវិជ្ជានិងចរណៈដ៏បរិបូណ៌ មានស្មារតីដំកល់មាំ រមែងលះបង់ទុក្ខ មានប្រមាណច្រើននេះ មិនខាន។

(បិ. ៥២ ទំ. ៥២)

១៤៥.១៧ **ឧទកំ ហិ នយន្តិ នេត្តិកា, ឧសុការា នមយន្តិ តេជនំ;**

**ទារុំ នមយន្តិ តច្ឆកា, អត្តានំ ទមយន្តិ សុព្វតា។**

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ(ឲ្យត្រង់) អ្នកចាំងតែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន។

(បិ. ៥២ ទំ. ៥២)

ចប់ទណ្ឌវគ្គ។

## ១១. ជរាវគ្គ

១៤៦.១ **កោ នុ ហាសោ កិមានន្ទោ, និច្ចំ បជ្ជលិតេ សតិ;**

**អន្ធការេន ឱនទ្ធា, បទីបំ ន គវេសថ។**

កាលបើលោកសន្និវាសត្រូវភ្លើងមានរាគៈជាដើម ឆេះទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកទាំងឡាយត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ(ម្តេចឡើយ)ក៏មិនស្វែងរកប្រទីបគឺប្រាជ្ញា។

(បិ. ៥២ ទំ. ៥២)

១៤៧.២ បស្ស ចិត្តកតំ ពិម្ពំ, អរុកាយំ សមុស្សិតំ;
អាតុរំ ពហុសង្កប្បំ, យស្ស នត្ថិ ធុវំ ឋិតិ។

អត្តភាពណា មិនទៀងទាត់ ឋិតថេរ អ្នកចូរមើលអត្តភាព(នោះ)ដែលកុសលាកុសលកម្ម ធ្វើវិចិត្រហើយ ជាកាយពាសពេញ ដោយដំបៅ ដែលឆ្អឹងបីរយកំណាត់ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះរបស់ជនច្រើនគ្នា។

(បិ. ៥២ ទំ. ៥៣)

១៤៨.៣ បរិជិណ្ណមិទំ រូបំ, រោគនិទ្ធំ បភង្គុណំ;
ភិជ្ជតិ បូតិសន្ទេហោ, មរណន្តំ ហិ ជីវិតំ។

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ ជារបស់ពុកផុយរាងកាយជារបស់ស្អុយ(នេះ) តែងបែកធ្លាយទៅវិញ ព្រោះថាជីវិតមានសេចក្តីស្លាប់ជាទីបំផុត។

(បិ. ៥២ ទំ. ៥៣)

១៤៩.៤ យានិមានិ អបត្ថានិ , អលាពូនេវ សារទេ;
កាបោតកានិ អដ្ឋីនិ, តានិ ទិស្វាន កា រតិ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ)ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ។

(បិ. ៥២ ទំ. ៥៣)

១៥០.៥ អដ្ឋីនំ នគរំ កតំ, មំសលោហិតលេបនំ;
យត្ថ ជរា ច មច្ចុ ច, មានោ មក្ខោ ច ឱហិតោ។

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្រីប្រកាន់ខ្លួននឹងសេចក្តីលុបគុណប្រជុំចុះក្នុងសរីរៈណា(សរីរៈនោះ)ដែលកុសលាកុសលកម្មធ្វើហើយឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់និងឈាម។

(បិ. ៥២ ទំ. ៥៣)

១៥១.៦ ជីរន្តិ វេ រាជរថា សុចិត្តា, អថោ សរីរម្បិ ជរំ ឧបេតិ;

សតញ្ច ធម្មោ ន ជរំ ឧបេតិ, សន្តោ ហវេ សព្ភិ បវេទយន្តិ។

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា ទើបឯធម៌របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា(ដូច្នោះទេ) សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន។

(បិ. ៥២ ទំ. ៥៣)

១៥២.៧ អប្បស្សុតាយំ បុរិសោ, ពលិពទ្ទោវ ជីរតិ;

មំសានិ តស្ស វឌ្ឍន្តិ, បញ្ញា តស្ស ន វឌ្ឍតិ។

បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់(ឥតអំពើ)ដូចគោបំរើសាច់របស់វាតែងចំរើនឡើង តែប្រាជ្ញារបស់វាមិនចំរើនឡើយ។

(បិ. ៥២ ទំ. ៥៤)

១៥៣.៨ អនេកជាតិសំសារំ, សន្ធាវិស្សំ អនិព្វិសំ;

គហការំ គវេសន្តោ, ទុក្ខា ជាតិ បុនប្បុនំ។

កាលតថាគតមិនទាន់បានជួបប្រទះ(ព្រះពោធិញ្ញាណ)រវល់តែស្វះស្វែងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាពក៏អន្ទោលទៅកាន់សង្សារវដ្តមានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ។

(បិ. ៥២ ទំ. ៥៤)

១៥៤.៩ គហការក ទិដ្ឋោសិ, បុន គេហំ ន កាហសិ;

សព្ពា តេ ផាសុកា ភគ្គា, គហកូដំ វិសង្ខតំ;

វិសង្ខារគតំ ចិត្តំ, តណ្ហានំ ខយមជ្ឈគា។

នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ(របស់តថាគត) ទៀតមិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់តថាគតកាច់បំបាក់ហើយ ដម្បូលផ្ទះគឺ អវិជ្ជា តថាគតកំចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ។

(បិ. ៥២ ទំ. ៥៤)

១៥៥.១០ អចរិត្វា ព្រហ្មចរិយំ, អលទ្ធា យោព្ពនេ ធនំ;

ជិណ្ណកោញ្ចាវ ឈាយន្តិ, ខីណមច្ឆេវ បល្ល លេ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅជាកំឡោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់ សំកុកនៅ ក្នុងភក់ដែលអស់ត្រីហើយ។

(បិ. ៥២ ទំ. ៥៤)

១៥៦.១១ អចរិត្វា ព្រហ្មចរិយំ, អលទ្ធា យោព្ពនេ ធនំ;

សេន្តិ ចាបាតិខីណាវ, បុរាណានិ អនុត្ថុនំ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅកំឡោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្លោះដូច្នោះ។

(បិ. ៥២ ទំ. ៥៤)

ចប់ជរាវគ្គ។

## ១២. អត្តវគ្គ

១៥៧. ១ អត្តានញ្ចេ បិយំ ជញ្ញា, រក្ខេយ្យ នំ សុរក្ខិតំ;

តិណ្ណំ អញ្ញតរំ យាមំ, បដិជគ្គេយ្យ បណ្ឌិតោ។

បើបណ្ឌិតដឹងខ្លួនថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយ។

(បិ. ៥២ ទំ. ៥៥)

១៥៨.២ អត្តានមេវ បឋមំ, បតិរូបេ និវេសយេ;

អថញ្ញមនុសាសេយ្យ, ន កិលិស្សេយ្យ បណ្ឌិតោ។

បណ្ឌិតគួរដម្កល់ខ្លួនទុកក្នុងគុណដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ(ធ្វើយ៉ាងនេះ)នឹងមិនលំបាកឡើយ។

(បិ. ៥២ ទំ. ៥៥)

១៥៩.៣ អត្តានំ ចេ តថា កយិរា, យថាញ្ញមនុសាសតិ;
សុទន្តោ វត ទមេថ, អត្តា ហិ កិរ ទុទ្ទមោ។

បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់។

(បិ. ៥២ ទំ. ៥៥)

១៦០.៤ អត្តា ហិ អត្តនោ នាថោ, កោ ហិ នាថោ បរោ សិយា;
អត្តនា ហិ សុទន្តេន, នាថំ លភតិ ទុល្លភំ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្ដេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹងដែលគេរកបានដោយកម្រ។

(បិ. ៥២ ទំ. ៥៥)

១៦១.៥ អត្តនា ហិ កតំ បាបំ, អត្តជំ អត្តសម្ភវំ;
អភិមត្ថតិ ទុម្មេធំ, វជិរំ វម្ហយំ មណឹ។

បាបកើតអំពីខ្លួន មានខ្លួនជាដែនកើតដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណីដែលកើតអំពីថ្មដូច្នោះឯង។

(បិ. ៥២ ទំ. ៥៥)

១៦២.៦ យស្ស អច្ចន្តទុស្សីល្យំ, មាលុវា សាលមិវោត្ថតំ;
ករោតិ សោ តថត្តានំ, យថា នំ ឥច្ឆតី ទិសោ។

ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់(នូវអត្តភាព)របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹត ដើមឈើ បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះ ឲ្យវិនាសដូច្នោះ។

(បិ. ៥២ ទំ. ៥៦)

១៦៣.៧ សុករានិ អសាធូនិ, អត្តនោ អហិតានិ ច;
យំ វេ ហិតញ្ច សាធុញ្ច, តំ វេ បរមទុក្ករំ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះដែលជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ដែលជនពាលធ្វើបានដោយលំបាក។

(បិ. ៥២ ទំ. ៥៦)

១៦៤.៨ យោ សាសនំ អរហតំ, អរិយានំ ធម្មជីវិនំ;
បដិក្កោសតិ ទុម្មេធោ, ទិដ្ឋឹ និស្សាយ បាបិកំ;
ផលានិ កដ្ឋកស្សេវ, អត្តឃញ្ញាយ ផល្លតិ។

បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនារបស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សីដូច្នោះ។

(បិ. ៥២ ទំ. ៥៦)

១៦៥.៩ អត្តនា វ កតំ បាបំ, អត្តនា សំកិលិស្សតិ;
អត្តនា អកតំ បាបំ, អត្តនាវ វិសុជ្ឈតិ;
សុទ្ធី អសុទ្ធិ បច្ចត្តំ, នាញ្ញោ អញ្ញំ វិសោធយេ។

អ្នកធ្វើបាបខ្លួនឯងនឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯងតែងបរិសុទ្ធស្អាតខ្លួនឯង សេចក្ដីបរិសុទ្ធិនឹងមិនបរិសុទ្ធិមានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធិពុំបានទេ។

(បិ. ៥២ ទំ. ៥៦)

១៦៦.១០ អត្តទត្ថំ បរត្ថេន, ពហុនាបិ ន ហាបយេ;
អត្តទត្ថមភិញ្ញាយ, សទត្ថបសុតោ សិយា។

បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួននោះ។

(បិ. ៥២ ទំ. ៥៧)

ចប់អត្តវគ្គ។

## ១៣. លោកវគ្គ

១៦៧.១ ហីនំ ធម្មំ ន សេវេយ្យ, បមាទេន ន សំវសេ;
មិច្ឆាទិដ្ឋឹ ន សេវេយ្យ, ន សិយា លោកវឌ្ឍនោ។

បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក។

(បិ. ៥២ ទំ. ៥៧)

១៦៨.២ ឧត្តិដ្ឋេ នប្បមជ្ជេយ្យ, ធម្មំ សុចរិតំ ចរេ;
ធម្មចារី សុខំ សេតិ, អស្មិំ លោកេ បរម្ហិ ច។

បុគ្គលមិនគួរប្រមាទក្នុងដុំបាយដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតីរមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង។

(បិ. ៥២ ទំ. ៥៧)

១៦៩.៣ ធម្មំ ចរេ សុចរិតំ, ន តំ ទុច្ចរិតំ ចរេ;
ធម្មចារី សុខំ សេតិ, អស្មិំ លោកេ បរម្ហិ ច។

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

(បិ. ៥២ ទំ. ៥៧)

១៧០.៤ យថា បុព្វុឡកំ បស្សេ, យថា បស្សេ មរីចិកំ;
ឯវំ លោកំ អវេក្ខន្តំ, មច្ចុរាជា ន បស្សតិ។

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្ងៃយ៉ាងណា ស្តេចមច្ចុរាជមិនឃើញអ្នកពិចារណា ខន្ធលោកជាដើម យ៉ាងនោះទេ។

(បិ. ៥២ ទំ. ៥៨)

១៧១.៥ ឯថ បស្សថិមំ លោកំ, ចិត្តំ រាជរថូបមំ;
យត្ថ ពាលា វិសីទន្តិ, នត្ថិ សង្គោ វិជានតំ។

អ្នកទាំងឡាយចូរមកមើលលោកនេះដ៏ត្រកាលដូចរាជរថ ជនពាលទាំងឡាយរមែងលិចលង់ក្នុងលោកណា សេចក្តីជាប់ជំពាក់ក្នុងលោកនេះរមែងមិនមានដល់ជនជាបណ្ឌិតទាំងឡាយ ដែលខ្លួនដឹងច្បាស់ទេ។

(បិ. ៥២ ទំ. ៥៨)

១៧២.៦ យោ ច បុព្វេ បមជ្ជិត្វា, បច្ឆា សោ នប្បមជ្ជតិ;
សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។

បុគ្គលណាមួយ កាលពីមុខប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញុំាំខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររះផុតចាកពពក។

(បិ. ៥២ ទំ. ៥៨)

១៧៣.៧ យស្ស បាបំ កតំ កម្មំ, កុសលេន បិធីយតិ ;
សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។

បុគ្គលណាធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយកុសលគឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថាញុំាំងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររះផុតចាកពពក។

(បិ. ៥២ ទំ. ៥៨)

១៧៤.៨ អន្ធភូតោ អយំ លោកោ, តនុកេត្ថ វិបស្សតិ;
សកុន្តោ ជាលមុត្តោវ, អប្បោ សគ្គាយ គច្ឆតិ។

លោកិយមហាជននេះជាមនុស្សងងឹតបណ្តាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ (នូវ ខន្ធាទិលោកនេះដោយអំណាចអនិច្ចលក្ខណៈជាដើម) ជនតិចគ្នា ដែលទៅកាន់ស្ថានសួគ៌ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ)តិចណាស់ដែលរួចអំពីសំណាញ់ដូច្នោះ។

(បិ. ៥២ ទំ. ៥៨)

១៧៥.៩ ហំសាទិច្ចបថេ យន្តិ, អាកាសេ យន្តិ ឥទ្ធិយា;

នីយន្តិ ធីរា លោកម្ហា, ជេត្វា មារំ សវាហនំ ។

ពួកហង្សតែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិតែងហោះទៅក្នុងអាកាសដោយឫទ្ធិ អ្នកប្រាជ្ញផ្ចាញ់កិលេសមារព្រមទាំងវាហនៈគឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន។

(បិ. ៥២ ទំ. ៥៩)

១៧៦.១០ ឯកំ ធម្មំ អតីតស្ស, មុសាវាទិស្ស ជន្តុនោ;
វិតិណ្ណបរលោកស្ស, នត្ថិ បាបំ អការិយំ។

បុគ្គលប្រព្រឹត្តកន្លង(ពាក្យសច្ចៈ)ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថាមិនធ្វើអំពើបាប មិនមែនឡើយ។

(បិ. ៥២ ទំ. ៥៩)

១៧៧.១១ ន វេ កទរិយា ទេវលោកំ វជន្តិ,
ពាលា ហវេ នប្បសំសន្តិ ទានំ;
ធីរោ ច ទានំ អនុមោទមានោ,
តេនេវ សោ ហោតិ សុខី បរត្ថ។

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយមិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញតែងអនុមោទនាទាន ព្រោះហេតុនោះលោកតែងបានសេចក្តីសុខក្នុង លោកខាងមុខ។

(បិ. ៥២ ទំ. ៥៩)

១៧៨.១២ បថព្យា ឯករជ្ជេន, សគ្គស្ស គមនេន វា;
សព្ពលោកាធិបច្ចេន, សោតាបត្តិផលំ វរំ។

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង។

(បិ. ៥២ ទំ. ៥៩)

ចប់លោកវគ្គ។

## ១៤. ពុទ្ធវគ្គ

១៧៩. ១ **យស្ស ជិតំ នាវជីយតិ, ជិតមស្ស នោ យាតិ កោចិ លោកេ;**

**តំ ពុទ្ធមនន្តគោចរំ, អបទំ កេន បទេន នេស្សថ។**

ជ័យជំនះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជំនះរបស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្តេចកើត។

(បិ. ៥២ ទំ. ៥៩)

១៨០.២ **យស្ស ជាលិនី វិសត្តិកា, តណ្ហា នត្ថិ កុហិញ្ចិ នេតវេ;**

**តំ ពុទ្ធំអនន្តគោចរំ, អបទំ កេន បទេន នេស្សថ។**

តណ្ហាដែលមានបណ្តាញផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចររកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្តេចកើត។

(បិ. ៥២ ទំ. ៦០)

១៨១.៣ **យេ ឈានបសុតា ធីរា, នេក្ខម្មូបសមេ រតា;**

**ទេវាបិ តេសំ បិហយន្តិ, សម្ពុទ្ធានំ សតីមតំ។**

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេតអរក្នុងនេក្ខម្មៈ ជាឋានស្ងប់រម្ងាប់កិលេស សូម្បីទេវតានឹងមនុស្សទាំងឡាយតែងរាប់រក ចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី ។

(បិ. ៥២ ទំ. ៦០)

១៨២.៤ **កិច្ឆោ មនុស្សបដិលាភោ, កិច្ឆំ មច្ចាន ជីវិតំ;**

**កិច្ឆំ សទ្ធម្មស្សវនំ, កិច្ឆោ ពុទ្ធានមុប្បាទោ។**

ការត្រឡប់បានអត្តភាពជាមនុស្សបានដោយកម្រ ការរស់សត្វទាំងឡាយបានដោយកម្រ ការស្តាប់ធម៌របស់សប្បុរសបានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយបានដោយកម្រ។

(បិ. ៥២ ទំ. ៦០)

១៨៣. ៥ សព្ពបាបស្ស អករណំ, កុសលស្ស ឧបសម្បទា ;
សចិត្តបរិយោទបនំ , ឯតំ ពុទ្ធាន សាសនំ។

ការមិនធ្វើបាបទាំងពួង ការញ៉ាំងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ។

(បិ. ៥២ ទំ. ៦០)

១៨៤.៦ ខន្តី បរមំ តបោ តិតិក្ខា,
និព្ពានំ បរមំ វទន្តិ ពុទ្ធា;
ន ហិ បព្ពជិតោ បរូបឃាតី,
ន សមណោ ហោតិ បរំ វិហេឋយន្តោ។

ខន្តី គឺសេចក្តីអត់ធន់ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយតែងពោលថា ព្រះព្រះនិព្វានជាធម្មជាតិដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថាបព្ពជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណៈឡើយ។

(បិ. ៥២ ទំ. ៦១)

១៨៥.៧ អនូបវាទោ អនូបឃាតោ, បាតិមោក្ខេ ច សំវរោ;
មត្តញ្ញុតា ច ភត្តស្មឹ, បន្តញ្ច សយនាសនំ;
អធិចិត្តេ ច អាយោគោ, ឯតំ ពុទ្ធាន សាសនំ។

ការមិនតិះដៀល១ ការមិនបៀតបៀន១ ការសង្រួមក្នុងបាតិមោក្ខ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត១ ការដេកនឹងអង្គុយក្នុងទីស្ងាត់១ ការព្យាយាមក្នុងអធិចិត្ត១ នុ៎ះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ។

(បិ. ៥២ ទំ. ៦១)

១៨៦.៨ ន កហាបណវស្សេន, តិត្តិ កាមេសុ វិជ្ជតិ;
អប្បស្សាទា ទុក្ខា កាមា, ឥតិ វិញ្ញាយ បណ្ឌិតោ។

ការស្កប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមានព្រោះកហាបណៈ(ដែលធ្លាប់ចុះ)ដូចទឹកភ្លៀងទេ កាមទាំងឡាយមានសុខតិចមានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់យ៉ាងនេះហើយ។

(បិ. ៥២ ទំ. ៦១)

១៨៧.៩ អបិ ទិព្ពេសុ កាមេសុ, រតឹ សោ នាធិគច្ឆតិ;

តណ្ហក្ខយរតោ ហោតិ, សម្មាសម្ពុទ្ធសាវកោ។

លោក(បណ្ឌិត)មិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បីជាទិព្វឡើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធរមែងជាអ្នកត្រេកអរក្នុងធម៌ជាគ្រឿងអស់តណ្ហា។

(បិ. ៥២ ទំ. ៦១)

១៨៨.១០ ពហុំ វេ សរណំ យន្តិ, បព្ពតានិ វនានិ ច;

អារាមរុក្ខចេត្យានិ, មនុស្សា ភយតជ្ជិតា។

មនុស្សទាំងឡាយច្រើននាក់ ត្រូវភ័យគម្រាមហើយ តែងយកភ្នំ អារាម និងរុក្ខចេតិយជាទីពឹង។

(បិ. ៥២ ទំ. ៦១)

១៨៩.១១ នេតំ ខោ សរណំ ខេមំ, នេតំ សរណមុត្តមំ;

នេតំ សរណមាគម្ម, សព្ពទុក្ខា បមុច្ចតិ។

ទីពឹងបែបនេះមិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះមិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ។

(បិ. ៥២ ទំ. ៦១)

១៩០.១២ យោ ច ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ គតោ;

ចត្តារិ អរិយសច្ចានិ, សម្មប្បញ្ញាយ បស្សតិ។

១៩១.១៣ ទុក្ខំ ទុក្ខសមុប្បាទំ, ទុក្ខស្ស ច អតិក្កមំ;

អរិយញ្ចដ្ឋង្គិកំ មគ្គំ, ទុក្ខូបសមគាមិនំ។

១៩២.១៤ ឯតំ ខោ សរណំ ខេមំ, ឯតំ សរណមុត្តមំ;
ឯតំ សរណមាគម្ម, សព្ពទុក្ខា បមុច្ចតិ។

លុះតែបុគ្គលណាយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ច ទាំង ៤ គឺ ទុក្ខសច្ច១ ទុក្ខសមុទយសច្ច១ និរោធសច្ច១ កន្លងទុក្ខ១ អរិយមគ្គប្រកបដោយអង្គ៨ ជាដំណើរទៅកាន់ព្រះព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ១ ដោយប្រាជ្ញដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន។

(បិ. ៥២ ទំ. ៦២)

១៩៣. ១៥ ទុល្លភោ បុរិសាជញ្ញោ, ន សោ សព្ពត្ថ ជាយតិ;
យត្ថ សោ ជាយតិ ធីរោ, តំ កុលំ សុខមេធតិ។

បុរសអាជានេយ្យរកបានដោយកម្រ លោកមិនកើតក្នុងសព្វឋានឡើយ លោកជាអ្នកមានប្រាជ្ញាកើតក្នុងត្រកូលណា ត្រកូលនោះតែងដល់នូវសេចក្តីសុខ។

(បិ. ៥២ ទំ. ៦២)

១៩៤.១៦ សុខោ ពុទ្ធានមុប្បាទោ, សុខា សទ្ធម្មទេសនា;
សុខា សង្ឃស្ស សាមគ្គី, សមគ្គានំ តបោ សុខោ។

ការកើតឡើងនៃព្រះពុទ្ធជាសុខ ការសំដែងព្រះសម្ធម្មជាសុខ សេចក្តីព្រមព្រៀងគ្នានៃពួកជាសុខ តបធម៌របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយជាសុខ។

(បិ. ៥២ ទំ. ៦២)

១៩៥.១៧ បូជារហេ បូជយតោ, ពុទ្ធេ យទិ វ សាវកេ;
បបញ្ចសមតិក្កន្តេ, តិណ្ណសោកបរិទ្ទវេ។

កាលបុគ្គលបូជាដល់បូជារហាបុគ្គលគឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោកនិងខ្សឹកខ្សួល។

(បិ. ៥២ ទំ. ៦២)

១៩៦.១៨ តេ តាទិសេ បូជយតោ, និព្វុតេ អកុតោភយេ;
ន សក្កា បុញ្ញំ សង្ខាតុំ, ឥមេត្តមបិ កេនចិ។

កាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះ បានឡើយ។

(បិ. ៥២ ទំ. ៦២)

ចប់ពុទ្ធវគ្គ ។

## ១៥. សុខវគ្គ

១៩៧. ១ សុសុខំ វត ជីវាម, វេរិនេសុ អវេរិនោ;
វេរិនេសុ មនុស្សេសុ, វិហរាម អវេរិនោ។

យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ។

(បិ. ៥២ ទំ. ៦៣)

១៩៨.២ សុសុខំ វត ជីវាម, អាតុរេសុ អនាតុរា;
អាតុរេសុ មនុស្សេសុ, វិហរាម អនាតុរា។

យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ(ដោយកិលេស)រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ។

(បិ. ៥២ ទំ. ៦៣)

១៩៩.៣ សុសុខំ វត ជីវាម, ឧស្សុកេសុ អនុស្សុកា;
ឧស្សុកេសុ មនស្សេសុ, វិហរាម អនុស្សុកា។

យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ កាលពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ។

(បិ. ៥២ ទំ. ៦៣)

២០០.៤ សុសុខំ វត ជីវាម, យេសន្នោ នត្ថិ កិញ្ចនំ;
បីតិភក្ខា ភវិស្សាម, ទេវា អាភស្សរា យថា។

យើងមិនមានកង្វល់តែងរស់នៅជាសុខពិត(ព្រោះ)យើងមានបីតិជាអាហារ ដូចពួកទេវតាជាន់ អភស្សរៈ។

(បិ. ៥២ ទំ. ៦៣)

២០១.៥ ជយំ វេរំ បសវតិ, ទុក្ខំ សេតិ បរាជិតោ;
ឧបសន្តោ សុខំ សេតិ, ហិត្វា ជយបរាជយំ។

បុគ្គលអ្នកឈ្នះតែងរងនៅពៀរ បុគ្គលអ្នកចាញ់តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះ នឹងការចាញ់ហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ។

(បិ. ៥២ ទំ. ៦៣)

២០២.៦ នត្ថិ រាគសមោ អគ្គិ, នត្ថិ ទោសសមោ កលិ;
នត្ថិ ខន្ធសមា ទុក្ខា, នត្ថិ សន្តិបរំ សុខំ។

ភ្លើងស្មើដោយរាគៈមិនមាន ទោសកំហុសស្មើដោយទោសៈមិនមាន ទុក្ខទាំងឡាយស្មើដោយខន្ធមិនមាន សុខក្រៅពីសេចក្តីស្ងប់មិនមាន។

(បិ. ៥២ ទំ. ៦៣)

២០៣.៧ ជិឃច្ឆាបរមា រោគា, សង្ខារា បរមា ទុខា;
ឯតំ ញត្វា យថាភូតំ, និព្ពានំ បរមំ សុខំ។

សេចក្តីស្រេកឃ្លានជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ)ដឹងច្បាស់សេចក្តីនុ៎ះ តាមពិតហើយ(រមែងធ្វើឲ្យច្បាស់)នូវព្រះព្រះនិព្វានជាសុខយ៉ាងក្រៃលែង។

(បិ. ៥២ ទំ. ៦៤)

២០៤.៨ អារោគ្យបរមា លាភា, សន្តុដ្ឋិបរមំ ធនំ;

វិស្សាសបរមា ញាតី, និព្ពានំ បរមំ សុខំ។

លាភមានការមិនមានរោគជាយ៉ាងក្រៃលែង ទ្រព្យមានសេចក្តីសន្តោសជាយ៉ាងក្រៃលែង ញាតិមានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង ព្រះព្រះនិព្វានជាសុខយ៉ាងក្រៃលែង។

(បិ. ៥២ ទំ. ៦៤)

២០៥.៩ បវិវេករសំ បិត្វា, រសំ ឧបសមស្ស ច;

និទ្ទរោ ហោតិ និប្បាបោ, ធម្មបីតិរសំ បិវំ។

ភិក្ខុផឹករសវិវេកផង រសព្រះព្រះនិព្វានផង ជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ។

(បិ. ៥២ ទំ. ៦៤)

២០៦.១០ សាធុ ទស្សនមរិយានំ, សន្និវាសោ សទា សុខោ;

អទស្សនេន ពាលានំ, និច្ចមេវ សុខី សិយា។

ការចួបប្រទះព្រះអរិយបុគ្គលទាំងឡាយជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខសព្វកាល បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ចបាន ព្រោះមិនចួបប្រទះបុគ្គលពាលទាំងឡាយ។

(បិ. ៥២ ទំ. ៦៤)

២០៧. ១១ ពាលសង្គតចារី ហិ, ទីឃមទ្ធាន សោចតិ;

ទុក្ខោ ពាលេហិ សំវាសោ, អមិត្តេនេវ សព្ពទា;

ធីរោ ច សុខសំវាសោ, ញាតីនំវ សមាគមោ។

បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខក្រៃលែង ដូចការនៅរួមជាមួយសត្រូវ ចំណែកខាងការនៅរួមនឹងធីរជនរមែងជាសុខ ដូចការចួបជុំនៃញាតិទាំងឡាយ។

(បិ. ៥២ ទំ. ៦៤-៦៥)

២០៨.១២ តស្មា ហិ ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច,
ធោរយ្ហសីលំ វតវន្តមរិយំ;
តំ តាទិសំ សប្បុរិសំ សុមេធំ,
ភជេថ នក្ខត្តបថំវ ចន្ទិមា ។

ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរសជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវ័តនឹងធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាជកដូច្នោះ ៗ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្ត-ឫក្ស។

(បិ. ៥២ ទំ. ៦៥)

ចប់សុខវគ្គ។

## ១៦. បិយវគ្គ

២០៩.១ អយោគេ យុញ្ជមត្តានំ, យោគស្មិញ្ច អយោជយំ;
អត្ថំ ហិត្វា បិយគ្គាហី, បិហេតត្តានុយោគិនំ។

បុគ្គលកាលប្រកបខ្លួនទុកក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួនក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់ បុគ្គលអ្នកប្រកបតាមខ្លួន។

(បិ. ៥២ ទំ. ៦៥)

២១០.២ មា បិយេហិ សមាគញ្ឆិ, អប្បិយេហិ កុទាចនំ;
បិយានំ អទស្សនំ ទុក្ខំ, អប្បិយានញ្ច ទស្សនំ។

កុំគប់រកសត្វនិងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ នឹងមិនជាទីស្រឡាញ់ក្នុងកាលណា ៗ ឡើយ ព្រោះថាការមិនចួបប្រសព្វសត្វនិងសង្ខារជាទីស្រឡាញ់ក្តី ការចួបប្រសព្វសត្វនិងសង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវទុក្ខ។

(បិ. ៥២ ទំ. ៦៥)

២១១.៣ តស្មា បិយំ ន កយិរាថ, បិយាបាយោ ហិ បាបកោ;
កន្ថា តេសំ ន វិជ្ជន្តិ, យេសំ នត្ថិ បិយាប្បិយំ។

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វនិងសង្ខារឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ព្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ជាសភាពអាក្រក់ ការស្រឡាញ់និងការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រេះទាំងឡាយ តែងមិនមានដល់ពួកជននោះ។

(បិ. ៥២ ទំ. ៦៦)

២១២.៤ បិយតោ ជាយតី សោកោ, បិយតោ ជាយតី ភយំ;
បិយតោ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាក សេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា។

(បិ. ៥២ ទំ. ៦៦)

២១៣.៥ បេមតោ ជាយតី សោកោ, បេមតោ ជាយតី ភយំ;
បេមតោ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា។

(បិ. ៥២ ទំ. ៦៦)

២១៤.៦ រតិយា ជាយតី សោកោ, រតិយា ជាយតី ភយំ;
រតិយា វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។

សេចក្តីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា។

(បិ. ៥២ ទំ. ៦៦)

២១៥.៧ **កាមតោ ជាយតី សោកោ, កាមតោ ជាយតី ភយំ;**

**កាមតោ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា។

(បិ. ៥២ ទំ. ៦៦)

២១៦.៨ **តណ្ហាយ ជាយតី សោកោ, តណ្ហាយ ជាយតី ភយំ;**

**តណ្ហាយ វិប្បមុត្តស្ស, នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា។

(បិ. ៥២ ទំ. ៦៦)

២១៧.៩ **សីលទស្សនសម្បន្នំ , ធម្មដ្ឋំ សច្ចវេទិនំ;**

**អត្តនោ កម្ម កុព្វានំ, តញ្ជនោ កុរុតេ បិយំ។**

ជនតែងធ្វើបុគ្គលដែលបរិបូណ៌ដោយសីលនិងការឃើញត្រូវ ឋិតនៅក្នុងធម៌ ពោលសច្ចធម៌ ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះឲ្យជាទីស្រឡាញ់។

(បិ. ៥២ ទំ. ៦៧)

២១៨.១០ **ឆន្ទជាតោ អនក្ខាតេ, មនសា ច ផុដោ សិយា;**

**កាមេសុ ច អប្បដិពទ្ធចិត្តោ, ឧទ្ធំសោតោតិ វុច្ចតិ។**

បុគ្គលអ្នកមានសេចក្តីប្រាថ្នាចំពោះព្រះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នាមិនបានផង ជាអ្នកមានមគ្គចិត្តនិងផលចិត្តប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ន្ធក្នុងកាមផង តថាគតហៅថាជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅក្នុងខាងលើ។

(បិ. ៥២ ទំ. ៦៧)

២១៩.១១ **ចិរប្បវាសឹ បុរិសំ, ទូរតោ សោត្ថិមាគតំ;**

**ញាតិមិត្តា សុហជ្ជា ច, អភិនន្ទន្តិ អាគតំ។**

ពួកញាតិក្តី មិត្រក្តី សំឡាញ់ក្តី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នា អស់កាលយូរមក អំពីចម្ងាយដោយសួស្តី មកដល់ហើយ។

(បិ. ៥២ ទំ. ៦៧)

២២០.១២ **តថេវ កតបុញ្ញម្បិ, អស្មា លោកា បរំ គតំ;**

**បុញ្ញានិ បដិគណ្ហន្តិ, បិយំ ញាតីវ អាគតំ។**

យ៉ាងណាមិញ បុណ្យទាំងឡាយតែងទទួលបុគ្គលដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្ស នេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយ ទទួលបុរសជាទីស្រឡាញ់ទើបមកដល់ ដូច្នោះឯង។

(បិ. ៥២ ទំ. ៦៧)

ចប់បិយវគ្គ។

## ១៧. កោធវគ្គ

២២១.១ **កោធំ ជហេ វិប្បជហេយ្យ មានំ, សំយោជនំ សព្ពមតិក្កមេយ្យ;**

**តន្នាមរូបស្មិ មសជ្ជមានំ, អកិញ្ចនំ នានុបតន្តិ ទុក្ខា។**

បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ ទាំងអស់ចោលចេញ ទុក្ខទាំងឡាយតែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ក្នុងនាមនិងរូប មិនមានកិលេស គ្រឿងកង្វល់នោះឡើយ។

(បិ. ៥២ ទំ. ៦៧-៦៨)

២២២.២ **យោ វេ ឧប្បតិតំ កោធំ, រថំ ភន្តំវ ធារយេ;**

**តមហំ សារថឹ ព្រូមិ, រស្មិគ្គាហោ ឥតរោ ជនោ។**

បុគ្គលណាឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុង លឿនបាន តថាគតហៅបុគ្គលនោះថាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ(មិន មែនសារថីឡើយ) ។

(បិ. ៥២ ទំ. ៦៨)

២២៣.៣ អក្កោធេន ជិនេ កោធំ, អសាធុំ សាធុនា ជិនេ;
ជិនេ កទរិយំ ទានេន, សច្ចេនាលិកវាទិនំ។

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយ សប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយមិនពិត ដោយពាក្យពិត។

(បិ. ៥២ ទំ. ៦៨)

២២៤.៤ សច្ចំ ភណេ ន កុជ្ឈេយ្យ, ទជ្ជា អប្បម្បិ យាចិតោ;
ឯតេហិ តីហិ ឋានេហិ, គច្ឆេ ទេវាន សន្តិកេ។

បុគ្គលគួរពោលពាក្យពិត១ មិនគួរក្រោធ១ កាលគេសូមវត្ថុសូម្បីមានតិច ក៏គួរឲ្យតាម តិច១ បុគ្គលគប្បីទៅកើតក្នុងសំណាក់ទេវតាទាំងឡាយបានដោយហេតុទាំង៣នេះឯង។

(បិ. ៥២ ទំ. ៦៨)

២២៥.៥ អហឹសកា យេ មុនយោ, និច្ចំ កាយេន សំវុតា;
តេ យន្តិ អច្ចុតំ ឋានំ, យត្ថ គន្ត្វា ន សោចរេ។

ជនទាំងឡាយណាជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ ជាដើម ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅ ដល់ហើយ តែងមិនសោកស្តាយ។

(បិ. ៥២ ទំ. ៦៨)

២២៦.៦ សទា ជាគរមានានំ, អហោរត្តានុសិក្ខិនំ;
និព្ពានំ អធិមុត្តានំ, អត្ថំ គច្ឆន្តិ អាសវា។

កាមាសវៈទាំងឡាយរបស់មនុស្ស អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំង ថ្ងៃទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ។

(បិ. ៥២ ទំ. ៦៩)

២២៧.៧ បោរាណមេតំ អតុល, នេតំ អជ្ជតនាមិវ;

និន្ទន្តិ តុណ្ហិមាសីនំ, និន្ទន្តិ ពហុភាណិនំ;
មិតភាណិម្បិ និន្ទន្តិ, នត្ថិ លោកេ អនិន្ទិតោ។

ម្នាលអតុលៈការតិះដៀលនឹងការសរសើរនេះជារបស់បូរាណ ការតិះដៀលនិងការសរសើរនេះ មិនមែនទើបនឹងកើតឡើយក្នុងថ្ងៃនេះទេ(ព្រោះថា)ជនទាំងឡាយតែងនិន្ទាបុគ្គលអ្នក អង្គុយស្ងៀមក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើនក៏មាន នន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន(បុគ្គលណាៗក៏ដោយ)ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ។

(បិ. ៥២ ទំ. ៦៩)

២២៨.៨ ន ចាហុ ន ច ភវិស្សតិ, ន ចេតរហិ វិជ្ជតិ;
ឯកន្តំ និន្ទិតោ បោសោ, ឯកន្តំ វា បសំសិតោ។

បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាងមិនមែនមានមកហើយតែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ។

(បិ. ៥២ ទំ. ៦៩)

២២៩.៩ យញ្ចេ វិញ្ញូ បសំសន្តិ, អនុវិច្ច សុវេ សុវេ;
អច្ឆិទ្ទវុត្តិំ មេធាវិំ, បញ្ញាសីលសមាហិតំ។

អ្នកប្រាជ្ញទាំងឡាយសង្កេតមើលរាល់ៗថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញាមានចិត្តដម្កល់ខ្ជាប់ក្នុងបញ្ញានិងសីល។

(បិ. ៥២ ទំ. ៦៩)

២៣០.១០ នេក្ខំជម្ពោនទស្សេវ, កោ តំ និន្ទិតុមរហតិ;
ទេវាបិ នំ បសំសន្តិ, ព្រហ្មុនាបិ បសំសិតោ។

អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាឆ្នោរនៃមាសជម្ពោនទនោះបាន ស្ដម្បីទេវតានិងមនុស្ស ទាំងឡាយក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរដូចគ្នា។

(បិ. ៥២ ទំ. ៦៩)

២៣១.១១ កាយប្បកោបំ រក្ខេយ្យ, កាយេន សំវុតោ សិយា;

កាយទុច្ចរិតំ ហិត្វា, កាយេន សុចរិតំ ចរេ។

បុគ្គលគប្បីរក្សានូវការចម្រើនកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត ។

(បិ. ៥២ ទំ. ៧០)

២៣២.១២ វចីបកោបំ រក្ខេយ្យ, វាចាយ សំវុតោ សិយា;

វចីទុច្ចរិតំ ហិត្វា, វាចាយ សុចរិតំ ចរេ។

បុគ្គលគប្បីរក្សានូវការចម្រើនវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត ។

(បិ. ៥២ ទំ. ៧០)

២៣៣.១៣ មនោបកោបំ រក្ខេយ្យ, មនសា សំវុតោ សិយា;

មនោទុច្ចរិតំ ហិត្វា, មនសា សុចរិតំ ចរេ។

គប្បីរក្សានូវការកម្រើនចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោ-សុចរិត។

(បិ. ៥២ ទំ. ៧០)

២៣៤.១៤ កាយេន សំវុតា ធីរា, អថោ វាចាយ សំវុតា;

មនសា សំវុតា ធីរា, តេ វេ សុបរិសំវុតា។

អ្នកប្រាជ្ញទាំងឡាយបានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយបានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថាសង្រួមហើយដោយប្រពៃ។

(បិ. ៥២ ទំ. ៧០)

ចប់កោធវគ្គ។

## ១៨. មលវគ្គ

២៣៥.១ បណ្ឌុបលាសោវ ទានិសិ, យមបុរិសាបិ ច តេ ឧបដ្ឋិតា;
ឧយ្យោគមុខេ ច តិដ្ឋសិ, បាថេយ្យម្បិ ច តេ ន វិជ្ជតិ។

ឥឡូវនេះខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់សេចក្តីវិនាស សូម្បីស្បៀងគឺកុសលរបស់អ្នកក៏មិនទាន់មានឡើយ។

(បិ. ៥២ ទំ. ៧០)

២៣៦.២ សោ ករោហិ ទីបមត្តនោ, ខិប្បំ វាយម បណ្ឌិតោ ភវ;
និទ្ធន្តមលោ អនង្គណោ, ទិព្ពំ អរិយភូមិមេហិសិ ។

អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នកធ្វើយ៉ាងនេះហើយ នឹងទៅជាអ្នកកំចាត់បង់មន្ទិលបានមិនមានទីទូលគឺកិលេសនឹងដល់នូវភូមិរបស់ព្រះអរិយៈដូចជាទិព្វបាន។

(បិ. ៥២ ទំ. ៧១)

២៣៧.៣ ឧបនីតវយោ ច ទានិសិ, សម្បយាតោសិ យមស្ស សន្តិកំ;
វាសោបិ ច តេ នត្ថិ អន្តរា, បាថេយ្យម្បិ ច តេ ន វិជ្ជតិ។

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សំណាក់យមរាជមួយទៀត ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ សូម្បីស្បៀងក៏មិនមានដល់អ្នក។

(បិ. ៥២ ទំ. ៧១)

២៣៨.៤ សោ ករោហិ ទីបមត្តនោ, ខិប្បំ វាយម បណ្ឌិតោ ភវ;
និទ្ធន្តមលោ អនង្គណោ, ន បុន ជាតិជរំ ឧបេហិសិ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នកធ្វើយ៉ាងនេះហើយ នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីទូលគឺកិលេសនឹងបានត្រូវចូលទៅ កាន់ជាតិ ជរា ព្យាធិ មរណៈទៀតហើយ។

(បិ. ៥២ ទំ. ៧១)

២៣៩.៥ អនុបុព្ពេន មេធាវី, ថោកំ ថោកំ ខណេ ខណេ;
កម្មារោ រជតស្សេវ, និទ្ធមេ មលមត្តនោ។

អ្នកមានប្រាជ្ញា គួរកំចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗខណៈដោយលំដាប់ ដូចជាងមាស ជំរះស្នឹមឬច្រែះរបស់មាសដូច្នោះ។

(បិ. ៥២ ទំ. ៧១)

២៤០.៦ អយសាវ មលំ សមុដ្ឋិតំ, តទុដ្ឋាយ តមេវ ខាទតិ;
ឯវំ អតិធោនចារិនំ, សានិ កម្មានិ នយន្តិ ទុគ្គតឹ។

ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួនតែងនាំបុគ្គលអ្នកប្រព្រឹត្ត កន្លងបញ្ញាជាគ្រឿងជំរះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង។

(បិ. ៥២ ទំ. ៧២)

២៤១.៧ អសជ្ឈាយមលា មន្តា, អនុដ្ឋានមលា ឃរា;
មលំ វណ្ណស្ស កោសជ្ជំ, បមាទោ រក្ខតោ មលំ។

មន្តទាំងឡាយមានការមិនស្វាធ្យាយន៍ជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំជាមន្ទិល សេចក្តីខ្ជិលជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទជាមន្ទិលរបស់បុគ្គលអ្នករក្សា។

(បិ. ៥២ ទំ. ៧២)

២៤២.៨ មលិត្ថិយា ទុច្ចរិតំ, មច្ឆេរំ ទទតោ មលំ;
មលា វេ បាបកា ធម្មា, អស្មឹ លោកេ បរម្ហិ ច។

ការប្រព្រឹត្តអាក្រក់ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ជារបស់អ្នកឲ្យ ធម៌អាក្រក់ជាមន្ទិល ក្នុងលោកនេះនិងលោកខាងមុខ។

(បិ. ៥២ ទំ. ៧២)

២៤៣.៩ តតោ មលា មលតរំ, អវិជ្ជា បរមំ មលំ;
ឯតំ មលំ បហន្ត្វាន, និម្មលា ហោថ ភិក្ខវោ។

ធម្មជាតិជាមន្ទិលដ៏លើសលុបជាងមន្ទិលទាំងនោះ គឺអវិជ្ជាជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ។

(បិ. ៥២ ទំ. ៧២)

២៤៤.១០ សុជីវំ អហិរិកេន, កាកសូរេន ធំសិនា;
បក្ខន្ទិនា បគព្ភេន, សំកិលិដ្ឋេន ជីវិតំ។

បុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្លៀវក្លាដូចសត្វក្អែក កំចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន ជាអ្នកឃ្នើសឃ្នងជាមនុស្សសៅហ្មង រស់ងនៅដោយងាយ។

(បិ. ៥២ ទំ. ៧២)

២៤៥.១១ **ហិរីមតា ច ទុជ្ជីវំ, និច្ចំ សុចិគវេសិនា;**
**អលីនេនាប្បគព្ភេន, សុទ្ធាជីវេន បស្សតា។**

ចំណែកបុគ្គលអ្នកមានសេចក្តីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនលេះលោះមិនឃ្នើស ឃ្នង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក។

(បិ. ៥២ ទំ. ៧២)

២៤៦.១២ **យោ បាណមតិបាតេតិ, មុសាវាទញ្ច ភាសតិ;**
**លោកេ អទិន្នមាទិយតិ, បរទារញ្ច គច្ឆតិ។**

ជនណាសំលាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឲ្យក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង។

(បិ. ៥២ ទំ. ៧៣)

២៤៧.១៣ **សុរាមេរយបានញ្ច, យោ នរោ អនុយុញ្ជតិ;**
**ឥធេវមេសោ លោកស្មឹ, មូលំ ខណតិ អត្តនោ។**

ជនណាផឹកទឹកសុរានិងមេរ័យផង ជននោះឯងឈ្មោះថា គាស់រំលើងឫសគល់របស់ខ្លួន ក្នុងលោកនេះ ដោយពិត។

(បិ. ៥២ ទំ. ៧៣)

២៤៨.១៤ **ឯវំ ភោ បុរិស ជានាហិ, បាបធម្មា អសញ្ញតា;**
**មា តំ លោភោ អធម្មោ ច, ចិរំ ទុក្ខាយ រន្ធយុំ។**

ម្នាលបុរសដ៏ចំរើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួមដូច្នេះ លោភៈនិងសភាពមិនមានធម៌គឺទោសៈ ចូរកុំបៀតបៀនអ្នកឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ។

(បិ. ៥២ ទំ. ៧៣)

២៤៩.១៥ **ទទាតិ វេ យថាសទ្ធំ, យថាបសាទនំ ជនោ;**
**តត្ថ យោ មង្កុតោ ហោតិ , បរេសំ បានភោជនេ;**

ន សោ ទិវា វា រត្តឹ វា, សមាធឹ អធិគច្ឆតិ។

ជនរមែងឲ្យតាមសទ្ធា តាមសេចក្ដីជ្រះថ្លា បុគ្គលណាជាអ្នកអៀនខ្មាសក្នុងទឹកនិងភោជន របស់ជនទាំងឡាយដទៃ ជននោះ រមែងមិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ។

(បិ. ៥២ ទំ. ៧៣)

២៥០.១៦ យស្ស ចេតំ សមុច្ឆិន្នំ, មូលឃច្ចំ សមូហតំ;

ស វេ ទិវា វា រត្តឹ វា, សមាធឹ អធិគច្ឆតិ។

លុះតែសេចក្ដីអៀនខ្មាសនោះ បុគ្គលណា បានផ្ដាច់ផ្ដិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្តក្នុងវេលាថ្ងៃឬក្នុងវេលាយប់។

(បិ. ៥២ ទំ. ៧៣)

២៥១.១៧ នត្ថិ រាគសមោ អគ្គិ, នត្ថិ ទោសសមោ គហោ;

នត្ថិ មោហសមំ ជាលំ, នត្ថិ តណ្ហាសមា នទី។

ភ្លើងស្មើដោយរាគៈមិនមាន ការចាប់ស្មើដោយទោសៈមិនមាន បណ្ដាញស្មើដោយមោហៈមិនមាន ស្ទឹងស្មើដោយតណ្ហាមិនមាន។

(បិ. ៥២ ទំ. ៧៣)

២៥២.១៨ សុទស្សំ វជ្ជមញ្ញេសំ, អត្តនោ បន ទុទ្ទសំ;

បរេសំ ហិ សោ វជ្ជានិ, ឱបុនាតិ យថា ភុសំ;

អត្តនោ បន ឆាទេតិ, កលឹវ កិតវា សឋោ។

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះបុគ្គលនោះ រោយទោសទាំងឡាយចំពោះអ្នកដទៃ ដូចបុគ្គលរោយអង្កាមដូន្នោះ តែថា រមែងបិទបាំងទោសរបស់ខ្លួនទុក ដូចព្រានបក្សីបិតបាំងអត្តភាពដោយវត្ថុសម្រាប់បិត បាំង មានមែកឈើជាដើម ដូច្នោះ។

(បិ. ៥២ ទំ. ៧៤)

២៥៣.១៩ បរវជ្ជានុបស្សិស្ស, និច្ចំ ឧជ្ឈានសញ្ញិនោ;
អាសវា តស្ស វឌ្ឍន្តិ, អារា សោ អាសវក្ខយា។

កាលបុគ្គលគយយ្លាំមើលទោសរបស់អ្នកដទៃជាប្រក្រតី មានការកត់សំគាល់ហេតុក្នុងការពោលទោសអ្នកដទៃ ជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចំរើន បុគ្គលនោះឈ្មោះថា ឋិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ។

(បិ. ៥២ ទំ. ៧៤)

២៥៤.២០ អាកាសេវ បទំ នត្ថិ, សមណោ នត្ថិ ពាហិរេ;
បបញ្ចាភិរតា បជា, និប្បបញ្ចា តថាគតា។

ស្នាមជើងក្នុងអាកាសមិនមាន សមណៈខាងក្រៅមិនមាន ពួកសត្វត្រេកអរហើយក្នុងធម៌យឺតយូរ ព្រះតថាគតទាំងឡាយមិនមានធម៌ជាគ្រឿងយឺតយូរឡើយ។

(បិ. ៥២ ទំ. ៧៤)

២៥៥.២១ អាកាសេវ បទំ នត្ថិ, សមណោ នត្ថិ ពាហិរេ;
សង្ខារា សស្សតា នត្ថិ, នត្ថិ ពុទ្ធានមិញ្ជិតំ។

ស្នាមជើងក្នុងអាកាសមិនមាន សាមណៈខាងក្រៅមិនមាន សង្ខារទាំងឡាយជារបស់ទៀងមិនមាន ព្រះពុទ្ធទាំងឡាយមិនមាន កិលេសជាគ្រឿងញាប់ញ័រទេ។

(បិ. ៥២ ទំ. ៧៤)

ចប់មលវគ្គ។

## ១៩. ធម្មដ្ឋវគ្គ

២៥៦.១ ន តេន ហោតិ ធម្មដ្ឋោ, យេនត្ថំ សាហសា នយេ;
យោ ច អត្ថំ អនត្ថញ្ច, ឧភោ និច្ឆេយ្យ បណ្ឌិតោ។

បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្តីទាំងពីរ ។

(បិ. ៥២ ទំ. ៧៥)

២៥៧.២ អសាហសេន ធម្មេន, សមេន នយតី បរេ;
ធម្មស្ស គុត្តោ មេធាវី, ធម្មដ្ឋោតិ បវុច្ចតិ។

គឺសេចក្តីពិត និងសេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ បុគ្គលនោះ ឈ្មោះថាជាអ្នកមានប្រាជ្ញា រក្សាធម៌ ទើបហៅថា អ្នកតាំងនៅក្នុងធម៌។

(បិ. ៥២ ទំ. ៧៥)

២៥៨.៣ ន តេន បណ្ឌិតោ ហោតិ, យាវតា ពហុ ភាសតិ;
ខេមី អវេរ អភយោ, បណ្ឌិតោតិ បវុច្ចតិ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មានភ័យ ទើបហៅថា បណ្ឌិតបាន។

(បិ. ៥២ ទំ. ៧៥)

២៥៩.៤ ន តាវតា ធម្មធរោ, យាវតា ពហុ ភាសតិ;
យោ ច អប្បម្បិ សុត្វាន, ធម្មំ កាយេន បស្សតិ;
ស វេ ធម្មធរោ ហោតិ, យោ ធម្មំ នប្បមជ្ជតិ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណោះ ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះមិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្តាប់ពុទ្ធ វចនៈ សូម្បីមានប្រមាណតិចហើយឃើញធម៌ដោយនាមកាយគឺចិត្តបាន បុគ្គលនោះទើបឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯងឈ្មោះថាជាអ្នកទ្រទ្រង់ធម៌។

(បិ. ៥២ ទំ. ៧៥)

២៦០.៥ ន តេន ថេរោ សោ ហោតិ , យេនស្ស បលិតំ សិរោ;
បរិបក្កោ វយោ តស្ស, មោឃជិណ្ណោតិ វុច្ចតិ។

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថាជាថេរៈដោយហេតុនោះមិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ ហៅថាចាស់ជាមោឃៈ។

(បិ. ៥២ ទំ. ៧៦)

២៦១.៦ យម្ហិ សច្ចញ្ច ធម្មោ ច, អហឹសា សំយមោ ទមោ;
ស វេ វន្តមលោ ធីរោ, ថេរោតិ បវុច្ចតិ។

លុះត្រាតែ សច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនឯងផង មានក្នុងបុគ្គលណា បុគ្គលនោះឯងជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ។

(បិ. ៥២ ទំ. ៧៦)

២៦២.៧ ន វាក្ករណមត្តេន, វណ្ណពោក្ខរតាយ វា;
សាធុរូបោ នរោ ហោតិ, ឥស្សុកី មច្ឆរី សឋោ។

បុគ្គលមានសេចក្តីឫស្យា មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថាជាមនុស្សល្អ ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យល្អ។

(បិ. ៥២ ទំ. ៧៦)

២៦៣.៨ យស្ស ចេតំ សមុច្ឆិន្នំ, មូលឃច្ចំ សមូហតំ;
ស វន្តទោសោ មេធាវី, សាធុរូបោតិ វុច្ចតិ។

លុះត្រាតែទោសជាតិ មានឫស្យាជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តល់ដកឡើងធ្វើឲ្យមាន ឫសគល់ដាច់ហើយ បុគ្គលនោះជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបថាជាមនុស្សល្អបាន។

(បិ. ៥២ ទំ. ៧៦)

២៦៤.៩ ន មុណ្ឌកេន សមណោ, អព្វតោ អលិកំ ភណំ;
ឥច្ឆាលោភសមាបន្នោ, សមណោ កឹ ភវិស្សតិ។

បុគ្គលមិនបានឈ្មោះថាជាសមណៈដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវ័តនិងធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នានឹងលោភៈ ឈ្មោះថាជាសមណៈដូចម្តេចបាន។

(បិ. ៥២ ទំ. ៧៦)

២៦៥.១០ យោ ច សមេតិ បាបានិ, អណុំ ថូលានិ សព្ពសោ;
សមិតត្តា ហិ បាបានំ, សមណោតិ បវុច្ចតិ។

លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយ ទាំងតូចទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថាសមណៈ ព្រោះបាបទាំងឡាយដែលបុគ្គលនោះរម្ងាប់បានហើយ។

(បិ. ៥២ ទំ. ៧៦)

២៦៦.១១ ន តេន ភិក្ខុ សោ ហោតិ, យាវតា ភិក្ខតេ បរេ;
វិស្សំ ធម្មំ សមាទាយ, ភិក្ខុ ហោតិ ន តាវតា។

បុគ្គលណា ដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបានឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមណោះទេ បុគ្គលសមាទានធមិជាពិស ឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះមិនទាន់បានទេ។

(បិ. ៥២ ទំ. ៧៧)

២៦៧.១២ យោធ បុញ្ញញ្ច បាបញ្ច, ពាហេត្វា ព្រហ្មចរិយវា;
សង្ខាយ លោកេ ចរតិ, ស វេ ភិក្ខូតិ វុច្ចតិ។

លុះត្រាតែបុគ្គលណា ក្នុងលោកនេះបន្សាត់បុណ្យនិងបាបចេញហើយ ជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរ ត្រាច់ទៅក្នុងលោកដោយសេចក្ដីចេះដឹង បុគ្គលនោះឯង ទើបហៅថាជាភិក្ខុ។

(បិ. ៥២ ទំ. ៧៧)

២៦៨.១៣ ន មោនេន មុនី ហោតិ, មូឡ្ហរូបោ អវិទ្ទសុ;
យោ ច តុលំវ បគ្គយ្ហ, វរមាទាយ បណ្ឌិតោ។

បុគ្គលមានសេចក្ដីវង្វេងជាធម្មតា មិនមានការចេះដឹងមិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណាជាបណ្ឌិតកាន់យកធមិដ៏ប្រសើរ វៀរចាកបាបទាំងឡាយ ។

(បិ. ៥២ ទំ. ៧៧)

២៦៩.១៤ បាបានិ បរិវជ្ជេតិ, ស មុនី តេន សោ មុនិ;

យោ មុនាតិ ឧភោ លោកេ,      មុនិ តេន បវុច្ចតិ។

ដូចបុគ្គលកាន់ជញ្ជីងហើយថ្លឹងដូច្នោះ បុគ្គលនោះទើបឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំងពីរ ក្នុងលោកបុគ្គលនោះ ហៅថាមុនីដោយហេតុនោះ។

(បិ. ៥២ ទំ. ៧៧)

២៧០.១៥ ន តេន អរិយោ ហោតិ,      យេន បាណានិ ហឹសតិ;

អហឹសា សព្ពបាណានំ,      អរិយោតិ បវុច្ចតិ។

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថាជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែលតថាគតហៅថា អរិយៈព្រោះមិនបៀតបៀនសត្វទាំងពួង។

(បិ. ៥២ ទំ. ៧៧)

២៧១.១៦ ន សីលព្ពតមត្តេន,      ពាហុសច្ចេន វា បន;

អថ វា សមាធិលាភេន,      វិវិត្តសយនេន វា។

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាលទុកចិត្តដោយគុណត្រឹមតែសីលនិងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ។

(បិ. ៥២ ទំ. ៧៨)

២៧២.១៧ ផុសាមិ នេក្ខម្មសុខំ,      អបុថុជ្ជនសេវិតំ;

ភិក្ខុ វិស្សាសមាបាទិ,      អប្បត្តោ អាសវក្ខយំ។

មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណេះថា អាត្មាអញ ពាល់ត្រូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ។

(បិ. ៥២ ទំ. ៧៨)

ចប់ធម្មដ្ឋវគ្គ។

## ២០. មគ្គវគ្គ

២៧៣.១ មគ្គានដ្ឋង្គិកោ សេដ្ឋោ, សច្ចានំ ចតុរោ បទា;

វិរាគោ សេដ្ឋោ ធម្មានំ, ទ្វិបទានញ្ច ចក្ខុមា។

ផ្លូវមានអង្គ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ៤ គឺអរិយសច្ចប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ ម្យ៉ាងទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ។

(បិ. ៥២ ទំ. ៧៨)

២៧៤.២ ឯសេវ មគ្គោ នត្ថញ្ញោ, ទស្សនស្ស វិសុទ្ធិយា;

ឯតញ្ហិ តុម្ហេ បដិបជ្ជថ, មារស្សេតំ បមោហនំ។

ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវញ៉ាំមារឲ្យវង្វេង។

(បិ. ៥២ ទំ. ៧៨)

២៧៥.៣ ឯតញ្ហិ តុម្ហេ បដិបន្នា, ទុក្ខស្សន្តំ ករិស្សថ;

អក្ខាតោ វោ មយា មគ្គោ, អញ្ញាយ សល្លសន្ថនំ ។

អ្នកទាំងឡាយដើរទៅកាន់ផ្លូវនេះហើយ អាចនឹងធ្វើឲ្យផុតទុក្ខបាន ផ្លូវនេះហើយ ដែលតថាគតថាជាផ្លូវកំចាត់បង់កូនសរ ប្រាប់អ្នកទាំងឡាយ។

(បិ. ៥២ ទំ. ៧៨)

២៧៦.៤ តុម្ហេហិ កិច្ចមាតប្បំ, អក្ខាតារោ តថាគតា;

បដិបន្នា បមោក្ខន្តិ, ឈាយិនោ មារពន្ធនា។

សេចក្តីព្យាយាមញ៉ាំងកិលេសឲ្យក្តៅសព្ទ អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន។

(បិ. ៥២ ទំ. ៧៨-៧៩)

២៧៧.៥ សព្ពេ សង្ខារា អនិច្ចាតិ, យទា បញ្ញាយ បស្សតិ;
អថ និព្ពិន្ទតិ ទុក្ខេ, ឯស មគ្គោ វិសុទ្ធិយា។

កាលណាបុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ។

(បិ. ៥២ ទំ. ៧៩)

២៧៨.៦ សព្ពេ សង្ខារា ទុក្ខាតិ, យទា បញ្ញាយ បស្សតិ;
អថ និព្ពិន្ទតិ ទុក្ខេ, ឯស មគ្គោ វិសុទ្ធិយា។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងនាំមកនូវសេចក្តីទុក្ខដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ។

(បិ. ៥២ ទំ. ៧៩)

២៧៩.៧ សព្ពេ ធម្មា អនត្តាតិ, យទា បញ្ញាយ បស្សតិ;
អថ និព្ពិន្ទតិ ទុក្ខេ, ឯស មគ្គោ វិសុទ្ធិយា។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ។

(បិ. ៥២ ទំ. ៧៩)

២៨០.៨ ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ,
យុវា ពលី អាលសិយំ ឧបេតោ;
សំសន្នសង្កប្បមនោ កុសីតោ,
បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ។

បុគ្គលនៅកំឡោះមានកំលាំង ទាស់តែប្រកមដោយសេចក្តីខ្ជិលច្រអូស មិនប្រឹងប្រែងក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះក្នុងចិត្ត លិចចុះ ក្នុងអកុសលវិតក្កៈ ជាមនុស្សខ្ជិល បុគ្គលខ្ជិលនោះរមែងមិនបានផ្លូវបញ្ញាឡើយ។

(បិ. ៥២ ទំ. ៧៩)

២៨១.៩ វាចានុរក្ខី មនសា សុសំវុតោ,
កាយេន ច អកុសលំ ន កយិរា;
ឯតេ តយោ កម្មបថេ វិសោធយេ,

## អាភជយេ មគ្គមិសិប្បវេទិតំ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អ ដោយមិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជំរះកម្មបទទាំង៣ នេះ នឹងគប្បីត្រេតអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណ ដ៏ល្អ សំដែងទុកហើយ។

(បិ. ៥២ ទំ. ៧៩)

២៨២.១០ យោគា វេ ជាយតី ភូរិ, អយោគា ភូរិសង្ខយោ;
ឯតំ ទ្វេធាបថំ ញត្វា, ភវាយ វិភវាយ ច;
តថាត្តានំ និវេសេយ្យ, យថា ភូរិ បវឌ្ឍតិ។

ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញាដឹងការប្រកប និងការមិនប្រកប ទាំពីរនេះថា ជាគន្លងនៃសេចក្តីចំរើន និងសេចក្តីវិនាសហើយ ប្រាជ្ញាចំរើនឡើយដោយប្រការណា គួរដំកល់ខ្លួនទុក ដោយប្រការនោះ។

(បិ. ៥២ ទំ. ៨០)

២៨៣.១១ វនំ ឆិន្ទថ មា រុក្ខំ, វនតោ ជាយតិ ភយំ;
ឆេត្វា វនញ្ច វនថញ្ច, និព្ពនា ហោថ ភិក្ខវោ។

អ្នកទាំងឡាយចូរកាត់កិលេសដូចជាព្រៃចេញ ចូរកំចាត់ដើមឈើ ព្រោះភ័យកើតអំពីកិលេស ដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃឈើផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង។

(បិ. ៥២ ទំ. ៨០)

២៨៤.១២ យាវ ហិ វនថោ ន ឆិជ្ជតិ, អណុមត្តោបិ នរស្ស នារិសុ;
បដិពទ្ធមនោវ តាវ សោ, វច្ឆោ ខីរបកោវ មាតរិ។

ចូរជាអ្នកកុំមានកិលេស ដូចជាព្រៃឡើយ ព្រោះថាកិលេសដូចជាព្រៃឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់កក្នុងពួកនារីដរាបណា នរជន

នោះឯង តែងមានចិត្តចំពោះក្នុងពួកនារី ដូចកូនគោនៅក្នុងបៅដោះ ដែលមានចិត្តជាប់នៅនឹងមេ ដរាបនោះ។

(បិ. ៥២ ទំ. ៨០)

២៨៥.១៣ ឧច្ឆិន្ទ សិនេហមត្តនោ កុមុទំ សារទិកំវ ចាណិនា;
សន្តិមគ្គមេវ ព្រូហយ, និព្ពានំ សុគតេន ទេសិតំ។

អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គល ដកផ្កាកុមុទ ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះព្រះនិព្វាន ព្រះសុគតសំដែងទុកហើយ។

(បិ. ៥២ ទំ. ៨០)

២៨៦.១៤ ឥធ វស្សំ វសិស្សាមិ, ឥធ ហេមន្តគិម្ហិសុ;
ឥតិ ពាលោ វិចិន្តេតិ, អន្តរាយំ ន ពុជ្ឈតិ។

អញនឹងនៅក្នុងទីនេះអស់វស្សានរដូវ អញនឹងនៅក្នុងទីនេះក្នុងហេមន្តរដូវនិងគិម្ហរដូវ ជនពាល រមែងគិតខុសដូច្នេះ តែងមិនដឹងច្បាស់សេចក្តីអន្តរាយឡើយ។

(បិ. ៥២ ទំ. ៨០)

២៨៧.១៥ តំ បុត្តបសុសម្មត្តំ, ព្យាសត្តមនសំ នរំ;
សុត្តំ គាមំ មហោឃោវ, មច្ចុ អាទាយ គច្ឆតិ។

មច្ចុគឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងជ្រប់ ក្នុងកូននិងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់។

(បិ. ៥២ ទំ. ៨១)

២៨៨.១៦ ន សន្តិ បុត្តា តាណាយ, ន បិតា នាបិ ពន្ធវា;
អន្តកេនាធិបន្នស្ស, នត្ថិ ញាតីសុ តាណតា។

កាលបុគ្គលត្រូវមច្ចុសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមាន ដើម្បីជាទីពឹងឡើយ ។

(បិ. ៥២ ទំ. ៨១)

២៨៩.១៧ ឯតមត្ថវសំ ញត្វា, បណ្ឌិតោ សីលសំវុតោ;
ព្រះនិព្វានគមនំ មគ្គំ, ខិប្បមេវ វិសោធយេ។

សេចក្តីទីពឹងក្នុងញាតិទាំងឡាយក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវជាទីកាន់ព្រះនិព្វានឲ្យបាន។

(បិ. ៥២ ទំ. ៨១)

ចប់មគ្គវគ្គ។

## ២១. បកិណ្ណកវគ្គ

២៩០.១ មត្តាសុខបរិច្ចាគា, បស្សេ ចេ វិបុលំ សុខំ;
ចជេ មត្តាសុខំ ធីរោ, សម្បស្សំ វិបុលំ សុខំ។

បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ។

(បិ. ៥២ ទំ. ៨១)

២៩១.២ បរទុក្ខូបធានេន, យោ អត្តនោ សុខមិច្ឆតិ;
វេរសំសគ្គសំសដ្ឋោ, វេរា សោ ន បរិមុច្ចតិ។

ជនប្រាថ្នាសេចក្តីសុខ ដើម្បីខ្លួន ដោយបង្កទុក្ខឲ្យអ្នកដទៃ ជននោះឈ្មោះថាច្រឡូកច្របល់ហើយ ដោយការជាប់ចំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ។

(បិ. ៥២ ទំ. ៨១)

២៩២.៣ យញ្ហិ កិច្ចំ តទបវិទ្ធំ, អកិច្ចំ បន ករិយតិ;
ឧន្នឡានំ បមត្តានំ, តេសំ វឌ្ឍន្តិ អាសវា។

របស់ណាដែលខ្លួនគួរធ្វើ របស់នោះពួកភិក្ខុណា លះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើ ត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចំរើនឡើងដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបុសលើកឡើយហើយ។

(បិ. ៥២ ទំ. ៨២)

២៩៣.៤ យេសញ្ច សុសមារទ្ធា, និច្ចំ កាយគតា សតិ;

អកិច្ចន្តេ ន សេវន្តិ, កិច្ចេ សាតច្ចការិនោ;

សតានំ សម្បជានានំ, អត្ថំ គច្ឆន្តិ អាសវា។

លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយរបស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែលដល់នូវការអស់ទៅ។

(បិ. ៥២ ទំ. ៨២)

២៩៤.៥ មាតរំ បិតរំ ហន្ត្វា, រាជានោ ទ្វេ ច ខត្តិយេ;

រដ្ឋំ សានុចរំ ហន្ត្វា, អនីឃោ យាតិ ព្រាហ្មណោ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានៈដូចមិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ដូចស្តេចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈដូចដែនដែន ប្រព្រឹត្តទៅមួយអន្លើដោយបុរសអ្នកដើរតាមគឺស្នៀនផង រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ។

(បិ. ៥២ ទំ. ៨២)

២៩៥.៦ មាតរំ បិតរំ ហន្ត្វា, រាជានោ ទ្វេ ច សោត្ថិយេ;

វេយគ្ឃបញ្ចមំ ហន្ត្វា, អនីឃោ យាតិ ព្រាហ្មណោ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានៈដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋ ដូចជាស្តេច ជាព្រាហ្មណ៍ទាំងពីរផង សម្លាប់វិចិកច្ឆា ដូចជាខ្លាធំជាគំរប់៥ផង បានហើយរមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ។

(បិ. ៥២ ទំ. ៨២)

២៩៦.៧ សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;

យេសំ ទិវា ច រត្តោ ច, និច្ចំ ពុទ្ធគតា សតិ។

សតិរបស់ជនណាដែលឋិតនៅក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជននោះឈ្មោះថាសាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល។

(បិ. ៥២ ទំ. ៨៣)

២៩៧.៨ សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;
យេសំ ទិវា ច រត្តោ ច, និច្ចំ ធម្មគតា សតិ។

សតិរបស់ជនណាដែលឋិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សព្វកាល។

(បិ. ៥២ ទំ. ៨៣)

២៩៨.៩ សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;
យេសំ ទិវា ច រត្តោ ច, និច្ចំ សង្ឃគតា សតិ។

សតិរបស់ជនណាដែលឋិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សព្វកាល។

(បិ. ៥២ ទំ. ៨៣)

២៩៩.១០ សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;
យេសំ ទិវា ច រត្តោ ច, និច្ចំ កាយគតា សតិ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថាសាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សព្វកាល។

(បិ. ៥២ ទំ. ៨៣)

៣០០.១១ សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;
យេសំ ទិវា ច រត្តោ ច, អហឹសាយ រតោ មនោ។

ចិត្តរបស់ជនពួកណាត្រេកអរហើយ ក្នុងការបៀតបៀនគេ ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថាសាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សព្វកាល។

(បិ. ៥២ ទំ. ៨៣)

៣០១.១២ សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;
យេសំ ទិវា ច រត្តោ ច, ភាវនាយ រតោ មនោ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងមេត្តាភាវនា ទាំងយប់ទាំងថ្ងៃ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល។

(បិ. ៥២ ទំ. ៨៣)

៣០២.១៣ ទុប្បព្ពជ្ជំ ទុរភិរមំ, ទុរាវាសា ឃរា ទុខា;

ទុក្ខោសមានសំវាសោ, ទុក្ខានុបតិតទ្ធគូ;

តស្មា ន ចទ្ធគូ សិយា, ន ច ទុក្ខានុបតិតោ សិយា ។

ការចេញបួសបានដោយកម្រ ការត្រេកអរត្រូវបានដោយក្រ ផ្ទះទាំងឡាយមានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្តៈ តែងត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាមផង។

(បិ. ៥២ ទំ. ៨៤)

៣០៣.១៤ សទ្ធោ សីលេន សម្បន្នោ, យសោភោគសមប្បិតោ;

យំ យំ បទេសំ ភជតិ, តត្ថ តត្ថេវ បូជិតោ។

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយសនិងភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ។

(បិ. ៥២ ទំ. ៨៤)

៣០៤.១៥ ទូរេ សន្តោ បកាសេន្តិ, ហិមវន្តោវ បព្ពតោ;

អសន្តេត្ថ ន ទិស្សន្តិ, រត្តឹ ខិត្តា យថា សរា។

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្តដូច្នោះ ពួកអសប្បុរសទុកជាឋិតនៅក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់។

(បិ. ៥២ ទំ. ៨៤)

៣០៥.១៦ ឯកាសនំ ឯកសេយ្យំ, ឯកោ ចរមតន្ទិតោ;

ឯកោ ទមយមត្តានំ, វនន្តេ រមិតោ សិយា។

បុគ្គល គួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់។

(បិ. ៥២ ទំ. ៨៤)

ចប់បកិណ្ណកវគ្គ។

## ២២. និរយវគ្គ

៣០៦.១ អភូតវាទី និរយំ ឧបេតិ, យោ វាបិ កត្វា ន ករោមិ ចាហ;

ឧភោបិ តេ បេច្ច សមា ភវន្តិ, និហីនកម្មា មនុជា បរត្ថ។

បុគ្គលពោលពាក្យមិនពិត ឬបុគ្គលណាធ្វើអំពើអាក្រក់ហើយនិយាយថា អញមិនធ្វើទេ បុគ្គលនោះ រមែងទៅកាន់នរក ជនទាំងពីរនាក់ ដែលមានអំពើទាបថោកស្មើគ្នានោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា ដោយគតិក្នុងលោកខាងមុខទៀត។

(បិ. ៥២ ទំ. ៨៥)

៣០៧.២ កាសាវកណ្ឋា ពហវោ, បាបធម្មា អសញ្ញតា;

បាបា បាបេហិ កម្មេហិ, និរយន្តេ ឧបបជ្ជរេ។

ពួកជនច្រើននាក់ដែលមានកព័ន្ធព័ទ្ធដោយសំពត់កាសាវៈ តែប្រព្រឹត្តធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះរមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ។

(បិ. ៥២ ទំ. ៨៥)

៣០៨.៣ សេយ្យោ អយោគុឡោ ភុត្តោ, តត្តោ អគ្គិសិខូបមោ;

យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ, រដ្ឋបិណ្ឌមសញ្ញតោ។

បព្ពជិតទ្រុស្តសីល ស្សូវបរិភោគដុំដែក ដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង បព្ពជិតទ្រុស្តសីល មិនសង្រួមបរិភោគដុំបាយអ្នកដែលនឹងប្រសើរ ដូចម្តេចបាន។

(បិ. ៥២ ទំ. ៨៥)

៣០៩.៤ ចត្តារិ ឋានានិ នរោ បមត្តោ, អាបជ្ជតិ បរទារូបសេវី;

អបុញ្ញលាភំ ច និកាមសេយ្យំ, និន្ទំ តតីយំ និរយំ ចតុត្ថំ។

នរជន អ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្ដីទុក្ខ ៤យ៉ាង គឺទី១បានរបស់មិនមែនជាបុណ្យ ទី២កមិនបានតាមប្រាថ្នា ទី៣ការតិះដៀល ទី៤ការធ្លាក់នរក។

(បិ. ៥២ ទំ. ៨៥)

៣១០.៥ អបុញ្ញលាភោ ច គតី ច បាបិកា,
ភីតស្ស ភីតាយ រតី ច ថោកិកា;
រាជា ច ទណ្ឌំ គរុកំ បណេតិ,
តស្មា នរោ បរទារំ ន សេវេ។

ហេតុនៃសេចក្ដីទុក្ខ៤យ៉ាងផ្សេងទៀតគឺ បានរបស់មិនជាបុណ្យ១ មានធម៌អាក្រក់១ តម្រេករបស់បុរសអ្នកខ្លាចជាមួយនឹងស្ត្រីដែលខ្លាច ដែរមានប្រមាណតិច១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់១ ព្រោះហេតុនោះបុរសមិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ។

(បិ. ៥២ ទំ. ៨៦)

៣១១.៦ កុសោ យថា ទុគ្គហិតោ, ហត្ថមេវានុកន្តតិ;
សាមញ្ញំ ទុប្បរាមដ្ឋំ, និរយាយុបកឌ្ឍតិ។

ស្បូវភ្លាំងដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃយ៉ាងណាមិញ ភាពជាសមណៈដែលបុគ្គល កាន់មិនស៊ប់សួនហើយ រមែងទាញបព្ពជិតនោះទៅនរក យ៉ាងនោះឯង។

(បិ. ៥២ ទំ. ៨៦)

៣១២.៧ យំ កិញ្ចិ សិថិលំ កម្មំ, សង្កិលិដ្ឋញ្ច យំ វតំ;
សង្កស្សរំ ព្រហ្មចរិយំ, ន តំ ហោតិ មហប្ផលំ។

កម្មណាមួយដែលធូរថយក្ដី វ័តណាមួយដែលសៅហ្មងក្ដី ព្រហ្មចរិយៈដែលបុគ្គលរឭកដោយសេចក្ដីរង្កៀសក្ដី កម្មទាំង៣ នោះ ជារបស់មិនមានផលច្រើនឡើយ។

(បិ. ៥២ ទំ. ៨៦)

៣១៣.៨ កយិរា ចេ កយិរាថេនំ, ទឡ្ហមេនំ បរក្កមេ;
សិថិលោ ហិ បរិព្ពាជោ, ភិយ្យោ អាកិរតេ រជំ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោលធូលីគឺរាគាទិក្កិលេសដល់បុគ្គលដោយក្រៃលែង។

(បិ. ៥២ ទំ. ៨៦)

៣១៤.៩ អកតំ ទុក្កដំ សេយ្យោ, បច្ឆា តប្បតិ ទុក្កតំ;
កតញ្ច សុកតំ សេយ្យោ, យំ កត្វា នានុតប្បតិ។

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើប្រសើរជាង ព្រោះថា អំពើអាក្រក់រមែងធ្វើឲ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពោះនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ។

(បិ. ៥២ ទំ. ៨៦)

៣១៥.១០ នគរំ យថា បច្ចន្តំ, គុត្តំ សន្តរពាហិរំ;
ឯវំ គោបេថ អត្តានំ, ខណោ វោ មា ឧបច្ចគា;
ខណាតីតា ហិ សោចន្តិ, និរយម្ហិ សមប្បិតា។

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅយ៉ាងណា អ្នកទាំងឡាយ គួររក្សាខ្លួនយ៉ាងណា កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថាជនទាំងឡាយ ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយក្នុងនរក មីរដេសដាស។

(បិ. ៥២ ទំ. ៨៧)

៣១៦.១១ អលជ្ជិតាយេ លជ្ជន្តិ, លជ្ជិតាយេ ន លជ្ជរេ;
មិច្ឆាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ ទុគ្គតិំ។

សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាសក្នុងហេតុដែលគេមិនត្រូវខ្មាស រមែងមិនខ្មាស ក្នុងហេតុដែលតែត្រូវខ្មាស សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ។

(បិ. ៥២ ទំ. ៨៧)

៣១៧.១២ អភយេ ភយទស្សិនោ, ភយេ ច អភយទស្សិនោ;

មិច្ឆាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ ទុគ្គតឹ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែលយល់ឃើញក្នុងហេតុដែលគេត្រូវខ្លាច ថាជាហេតុដែលគេមិនត្រូវខ្លាចផង សត្វទាំងនោះតែងទៅកាន់ទុគ្គតិ។

(បិ. ៥២ ទំ. ៨៧)

៣១៨.១៣ អវជ្ជេ វជ្ជមតិនោ, វជ្ជេ ច អវជ្ជទស្សិនោ;

មិច្ឆាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ ទុគ្គតឹ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញក្នុងហេតុដែលមានទោស ថាជាហេតុឥតទោសផង សត្វទាំងនោះតែងទៅកាន់ទុគ្គតិ។

(បិ. ៥២ ទំ. ៨៧)

៣១៩.១៤ វជ្ជញ្ច វជ្ជតោ ញត្វា, អវជ្ជញ្ច អវជ្ជតោ;

សម្មាទិដ្ឋិសមាទានា, សត្តា គច្ឆន្តិ សុគ្គតឹ។

សត្វទាំងឡាយដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់ សុគតិ។

(បិ. ៥២ ទំ. ៨៨)

និរយវគ្គ។

## ២៣. នាគវគ្គ

៣២០.១ អហំ នាគោវ សង្គាមេ, ចាបតោ បតិតំ សរំ;

អតិវាក្យន្តិតិក្ខិស្សំ, ទុស្សីលោ ហិ ពហុជ្ជនោ។

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាល់អត់ទ្រាំចំពោះព្រួញដែលរបូតចេញអំពីធ្នូក្នុងសង្រ្គាមដូច្នេះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់។

(បិ. ៥២ ទំ. ៨៨)

៣២១.២ *ទន្តំ នយន្តិ សមិតិំ, ទន្តំ រាជាភិរូហតិ;*

*ទន្តោ សេដ្ឋោ មនុស្សេសុ, យោតិវាក្យន្តិតិក្ខតិ។*

ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើយកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត។

(បិ. ៥២ ទំ. ៨៨)

៣២២.៣ *វរមស្សតរា ទន្តា, អាជានីយា ច សិន្ធវា;*

*កុញ្ជរា ច មហានាគា, អត្តទន្តោ តតោ វរំ។*

ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀន ប្រដៅបានបទហើយ រាប់ថាជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានបទហើយប្រសើរ ជាងសត្វទាំងអស់នោះ។

(បិ. ៥២ ទំ. ៨៨)

៣២៣.៤ *ន ហិ ឯតេហិ យានេហិ, គច្ឆេយ្យ អគតំ ទិសំ;*

*យថាត្តនា សុទន្តេន, ទន្តោ ទន្តេន គច្ឆតិ។*

បុគ្គលទូន្មានខ្លួនបានបទហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថាទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅគឺព្រះព្រះនិញ្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ។

(បិ. ៥២ ទំ. ៨៩)

៣២៤.៥ *ធនបាលកោ នាម កុញ្ជរោ, កដុកប្បភេទនោ ទុន្និវារយោ;*

*ពទ្ធោ កពឡំ ន ភុញ្ជតិ, សុមរតិ នាគវនស្ស កុញ្ជរោ។*

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង គៀរក្លា នាយហត្ថាចារ្យឃាត់បានដោយលំបាក ហើយនាយហត្ថាចារ្យ ចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ទឹង ដែលដំរីនោះធ្លាប់ទៅ។

(បិ. ៥២ ទំ. ៨៩)

៣២៥. ៦ មិទ្ធី យទា ហោតិ មហគ្ឃសោ ច,

និទ្ទាយិតា សម្បរិវត្តសាយី;

មហាវរាហោវ និវាបបុដ្ឋោ,

បុនប្បុនំ គព្ភមុបេតិ មន្ទោ។

កាលណា បុគ្គលអ្នកមានសេចក្តីងោកងុយផង អ្នបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះននៀលផង ដូចជ្រូកស្រុក ដែលបុគ្គលចិញ្ចឹមដោយសុករភត្ត កាលនោះបុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គតិរឿយៗ។

(បិ. ៥២ ទំ. ៨៩)

៣២៦.៧ ឥទំ បុរេ ចិត្តមចារិ ចារិកំ,

យេនិច្ឆកំ យត្ថកាមំ យថាសុខំ;

តទជ្ជហំ និគ្គហេស្សាមិ យោនិសោ,

ហត្ថិប្បភិន្នំ វិយ អំកុសគ្គហោ។

ក្នុងកាលមុនអំពីកាននេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូន្នោះដែរ។

(បិ. ៥២ ទំ. ៨៩)

៣២៧.៨ អប្បមាទរតា ហោថ, សចិត្តមនុរក្ខថ;

ទុគ្គា ឧទ្ធរថត្តានំ, បង្កេ សន្នោវ កុញ្ជរោ។

អ្នកទាំងឡាយចូរត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូរវើខ្លួនចេញចាកភក់ គឺកិលេស ដែលឆ្លងបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងភក់ វើខ្លួនឲ្យរួចបាន។

(បិ. ៥២ ទំ. ៩០)

៣២៨.៩ សចេ លភេថ និបកំ សហាយំ,

សទ្ធិំ ចរំ សាធុវិហារិធីរំ;

អភិភុយ្យ សព្ពានិ បរិស្សយានិ,

ចរេយ្យ តេនត្តមនោ សតីមា។

បើបុគ្គលបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធមិជាគ្រឿងនៅញុំាំប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសំឡាញនោះឯង។

(បិ. ៥២ ទំ. ៩០)

៣២៩.១០ នោ ចេ លភេថ និបកំ សហាយំ,

សទ្ធិំ ចរំ សាធុវិហារិធីរំ;

រាជាវ រដ្ឋំ វិជិតំ បហាយ,

ឯកោ ចរេ មាតង្គរញ្ញេវ នាគោ។

បើស្វែងរកមិនបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធមិជាគ្រឿងញុំាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រេតទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំ នោះសោត ដូចដំរីឈ្មោះមាតង្គៈ ដែលលះហ្វូងត្រាច់ទៅជាឯកឯងក្នុងព្រៃ ដូច្នោះដែរ។

(បិ. ៥២ ទំ. ៩០)

៣៣០.១១ ឯកស្ស ចរិតំ សេយ្យោ,

នត្ថិ ពាលេ សហាយតា;

ឯកោ ចរេ ន ច បាបានិ កយិរា,
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ។

ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតប្រសើរបំផុត ព្រោះថាសហាយតាគុណ រមែង មិនមាន ក្នុងជនពាលឡើយ បុគ្គលនោះគប្បីជាអ្នកមិនសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯងក្នុងព្រៃ ដូច្នោះដែរ។

(បិ. ៥២ ទំ. ៩០)

៣៣១.១២ អត្ថម្ហិ ជាតម្ហិ សុខា សហាយា,
តុដ្ឋី សុខា យា ឥតរីតរេន;
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ,
សព្ពស្ស ទុក្ខស្ស សុខំ បហានំ។

កាលបើសេចក្តីត្រូវការ កើតឡើយហើយ សំឡាញ់ទាំងឡាយនាំសេចក្តីសុខមកឲ្យ សេចក្តីត្រេតអរដោយបច្ច័យ តាមមានតាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យ ក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ។

(បិ. ៥២ ទំ. ៩១)

៣៣២.១៣ សុខា មត្តេយ្យតា លោកេ, អថោ បេត្តេយ្យតា សុខា;
សុខា សាមញ្ញតា លោកេ, អថោ ព្រហ្មញ្ញតា សុខា។

សេចក្តីប្រត្រិបត្តិលល្អក្នុងមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀតសេចក្តីប្រតិបត្តិល្អក្នុងបិតា នាំសេចក្តីសុខមកឲ្យ សេចក្តីប្រតិបត្តិកល្អក្នុងព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ។

(បិ. ៥២ ទំ. ៩១)

៣៣៣.១៤ សុខំ យាវ ជរា សីលំ, សុខា សទ្ធា បតិដ្ឋិតា;

**សុខោ បញ្ញាយ បដិលាភោ, ចាចានំ អករណំ សុខំ។**

សីលនាំសេចក្ដីសុខមកឲ្យដរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្ដី សុខមកឲ្យ ការបានប្រាជ្ញា នាំសេចក្ដីសុខមកឲ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្ដីសុខមកឲ្យ។

(បិ. ៥២ ទំ. ៩១)

ចប់នាគវគ្គ។

**២៤. តណ្ហាវគ្គ**

៣៣៤.១ **មនុជស្ស បមត្តចារិនោ, តណ្ហា វឌ្ឍតិ មាលុវា វិយ;**

**សោ បលវេតី ហុរា ហុរំ, ផលមិច្ឆំវ វនស្មឹ វានរោ។**

តណ្ហាតែងចំរើនដល់មនុស្សអ្នកមានការប្រព្រឹត្ត ដោយសេចក្ដីប្រមាទជាប្រក្រតី ដូចវល្លិ៍រូបរឹត ឈើហើយចំរើនឡើង បុគ្គលនោះតែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើលោតក្នុងព្រៃ ដូន្នោះដែរ។

(បិ. ៥២ ទំ. ៩១)

៣៣៥.២ **យំ ឯសា សហតី ជម្មី, តណ្ហា លោកេ វិសត្តិកា;**

**សោកា តស្ស បវឌ្ឍន្តិ, អភិវឌ្ឍំវ វីរណំ។**

តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងការម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្ដីសោកស្ដាយ តែងចំរើនឡើងដល់បុគ្គលនោះដូចស្បូវណ្ដាស ដែលត្រូវភ្លៀងធ្លាក់ ចុះជញ្ជ្រាំហើយពន្លក លូតលេចឡើង ដូច្នោះដែរ។

(បិ. ៥២ ទំ. ៩២)

៣៣៦.៣ **យោ ចេតំ សហតី ជម្មឹ, តណ្ហំ លោកេ ទុរច្ចយំ;**

**សោកា តម្ហា បបតន្តិ, ឧទពិន្ទុវ បោក្ខរា។**

ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមក ក្នុងលោក ដែលគេឆ្លងបានដោយកម្រ នោះ សេចក្តីសោកស្តាយ តែងធ្លាប់ចេញចាកជននោះឯង ដូចដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ។

(បិ. ៥២ ទំ. ៩២)

៣៣៧.៤ តំ វោ វទាមិ ភទ្ទំ វោ, យាវន្តេត្ថ សមាគតា;

តណ្ហាយ មូលំ ខណថ, ឧសីរត្ថោវ វីរណំ;

មា វោ នឡំវ សោតោវ, មារោ ភញ្ជិ បុនប្បុនំ។

ព្រោះហេតុនោះបានជាតថាគត ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមក ប្រជុំក្នុងទីនេះ សេចក្តីចំរើនចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររំលើងឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្បូវភ្លាំង គាស់ស្បូវណ្តាសចោលចេញ ដូច្នោះ មារកុំរុករានអ្នកទាំងឡាយរឿយៗ ដូចខ្សែទឹក កាច់បំបាក់ដើមបបុសដូច្នោះឡើយ។

(បិ. ៥២ ទំ. ៩២)

៣៣៨.៥ យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ,

ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ;

ឯវម្បិ តណ្ហានុសយេ អនូហតេ,

និព្វត្តតី ទុក្ខមិទំ បុនប្បុនំ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើយទៀតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុស្ស័យ បុគ្គលកំចាត់មិនទាន់បានហើយ ទុក្ខនេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង។

(បិ. ៥២ ទំ. ៩២)

៣៣៩.៦ យស្ស ឆត្តឹសតិ សោតា, មនាបសវនា ភុសា;

មាហា វហន្តិ ទុទ្ទិដ្ឋឹ, សង្កប្បា រាគនិស្សិតា។

ខ្សែតណ្ហា៣៦ ជាធម្មជាតិហូរទៅ ក្នុងការម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់ របស់បុគ្គលនោះ។

(បិ. ៥២ ទំ. ៩៣)

៣៤០.៧ សវន្តិ សព្ពធិ សោតា, លតា ឧព្ភិជ្ជ តិដ្ឋតិ;

តញ្ច ទិស្វា លតំ ជាតំ, មូលំ បញ្ញាយ ឆិន្ទថ។

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅ ក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិដែលបែកខ្នែងឡើងតាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញតណ្ហាដូចវល្លិនោះ កើតឡើយហើយ ចូរកាត់ឫសចោលចេញ ដោយកាំបិតបញ្ញា។

៣៤១.៨ សរិតានិ សិនេហិតានិ ច, សោមនស្សានិ ភវន្តិ ជន្តុនោ;

តេ សាតសិតា សុខេសិនោ, តេ វេ ជាតិជរូបគា នរា។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្តីរីករាយ អ្នកស្វែងរកសេចក្តីសុខ នរជនទាំងឡាយនោះឯង តែងឈមទៅរកជាតិនិងជរា។

(បិ. ៥២ ទំ. ៩៣)

៣៤២.៩ តសិណាយ បុរក្ខតា បជា, បរិសប្បន្តិ សសោវ ពាធិតោ ;

សញ្ញោជនសង្គសត្តា, ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ។

ពួកសត្វដែលតណ្ហា ជាទីញាំងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ដូចទន្សាយដែល ព្រានទាក់បានហើយដូច្នោះ ពួកសត្វ ដែលជាប់ក្នុងសំយោជនៈនិងសង្គធម៌(ធម៌ជាគ្រឿងជំពាក់) តែងដល់នូវសេចក្តីទុក្ខរឿងៗ អស់កាលអង្វែង។

(បិ. ៥២ ទំ. ៩៣)

៣៤៣.១០ តសិណាយ បុរក្ខតា បជា, បរិសប្បន្តិ សសោវ ពន្ធិតោ;

តស្មា តសិណំ វិនោទយេ, ភិក្ខុ អាកង្ខំ វិរាគមត្តនោ។

ពួកសត្វដែលតណ្ហា ជាទីញាំងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ដូចទន្សាយដែលនាយព្រាន ទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធមិជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុតចោលចេញ។

(បិ. ៥២ ទំ. ៩៥)

៣៩៤.១១ យោ និព្វនថោ វនាធិមុត្តោ, វនមុត្តោ វនមេវ ធាវតិ;

តំ បុគ្គលមេថ បស្សថ, មុត្តោ ពន្ធនមេវ ធាវតិ។

បុគ្គលណាមិនមានអាល័យក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃគឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃគឺតណ្ហា ហើយស្ទុះទៅរកព្រៃគឺតណ្ហាវិញ អ្នកទាំងឡាយចូរមើលបុគ្គលនោះឯង បុគ្គលនោះរួចចាកចំណងគឺឃរាវាសហើយ ស្ទុះទៅរកចំណងគឺឃរាវាសវិញ។

(បិ. ៥២ ទំ. ៩៥)

៣៩៥.១២ ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា,

យទាយសំ ទារុជំ ពព្វជញ្ច;

សារត្តរត្តា មណិកុណ្ឌលេសុ,

បុត្តេសុ ទារេសុ ច យា អបេក្ខា។

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅយាប្លងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះ ថាជាចំណងមាំមួនឡើយ ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណីនិងគុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យកូននិងប្រពន្ធទាំងឡាយក្តី។

(បិ. ៥២ ទំ. ៩៥)

៣៩៦.១៣ ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា, ឱហារិនំ សិថិលំ ទុប្បមុញ្ចំ;

ឯតម្បិ ឆេត្វាន បរិព្ពជន្តិ, អនបេក្ខិនោ កាមសុខំ បហាយ។

អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្តីត្រេកអរនិងសេចក្តីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំចុះ ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញ

ទាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្ដីអាឡោះអាល័យ លះបង់កាមសុខ ហើយចេញបួស។

(បិ. ៥២ ទំ. ៩៤)

៣៤៧.១៤ យេ រាគរត្តានុបតន្តិ សោតំ, សយំកតំ មក្កដកោវ ជាលំ;

ឯតម្បិ ឆេត្វាន វជន្តិ ធីរា, អនបេក្ខិនោ សព្ពទុក្ខំ បហាយ។

ពួកជនណាត្រេកអរដោយអំណាចរាគៈ ពួកជននោះតែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាង ទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាន់ខ្សែ តណ្ហានោះ ជាអ្នកមិនមានសេចក្ដីអាឡោះអាល័យ លះបង់ទាំងពួងចេញទៅ។

(បិ. ៥២ ទំ. ៩៥)

៣៤៨.១៥ មុញ្ច បុរេ មុញ្ច បច្ឆតោ, មជ្ឈេ មុញ្ច ភវស្ស បារគូ;

សព្ពត្ថ វិមុត្តមានសោ, ន បុន ជាតិជរំ ឧបេហិសិ។

អ្នកចូរដោះសេចក្ដីអាល័យក្នុងកាលមុនចេញ ចូរដោះសេចក្ដីអាល័យក្នុងខាងក្រៅចេញ ចូរដោះសេចក្ដីអាល័យក្នុងកាលជាកណ្ដាលចេញ កាលបើធ្វើយ៉ាងនេះ អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រឡះចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិនិងជរាទៀតហើយ។

(បិ. ៥២ ទំ. ៩៥)

៣៤៩.១៦ វិតក្កមថិតស្ស ជន្តុនោ, តិព្ពរាគស្ស សុភានុបស្សិនោ;

ភិយ្យោ តណ្ហា បវឌ្ឍតិ, ឯស ខោ ទឡ្ហំ ករោតិ ពន្ធនំ។

តណ្ហារមែងចំរើនក្រៃលែង ដល់ជនដែលវិត្តកៈញាំញី មានតម្រេកក្លៀងក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯងឈ្មោះថាធ្វើបំណងឲ្យមាំមួន ។

(បិ. ៥២ ទំ. ៩៥)

៣៥០.១៧ វិតក្កូបសមេ ច យោ រតោ, អសុភំ ភាវយតី សទា សតោ;

ឯស ខោ ព្យន្តិ កាហិតិ, ឯសច្ឆេច្ឆតិ មារពន្ធនំ។

លុះតែបុគ្គលណា ត្រេកអរក្នុង អសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់នូវវិតក្កៈ មានស្មារតីសព្វកាល តែងចំរើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន។

(បិ. ៥២ ទំ. ៩៥)

៣៥១.១៨ និដ្ឋង្គតោ អសន្តាសី, វីតតណ្ហោ អនង្គណោ;
អច្ឆិន្ទិ ភវសល្លានិ, អន្តិមោយំ សមុស្សយោ។

បុគ្គលណាដល់សេចក្តីសម្រេចគឺអរហន្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់កូនសរគឺកិលេស ជាហេតុញ៉ាំងសត្វឲ្យទៅកាន់ភពបានហើយ កាយដែលឆ្អឹង៣០០ កំណាត់ផ្គុំគ្នាហើយនេះ របស់បុគ្គលនោះ ឈ្មោះថាតាំងនៅក្នុងទីបំផុត។

(បិ. ៥២ ទំ. ៩៦)

៣៥២.១៩ វីតតណ្ហោ អនាទានោ, និរុត្តិបទកោវិទោ;
អក្ខរានំ សន្និបាតំ, ជញ្ញា បុព្ពាបរានិ ច;
ស វេ អន្តិមសារីរោ, មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ។

បុគ្គលណាមិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាសក្នុងនិរុត្តិ(វាចាជាគ្រឿងសំដែងចេញ)និងបទដ៏វិសេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាងផង នូវខាងដើមនិងខាងចុងនៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថា អ្នកមានសរីរៈឋិតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស។

(បិ. ៥២ ទំ. ៩៦)

៣៥៣.២០ សព្ពាភិភូ សព្ពវិទូហមស្មិ,
សព្ពេសុ ធម្មេសុ អនូបលិត្តោ;
សព្ពញ្ជហោ តណ្ហាក្ខយេ វិមុត្តោ,
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ។

តថាគតជាអ្នកគ្របសង្កត់តេភូមិកធម៌ទាំងអស់ ដឹងច្បាស់ចតុព្វបិកធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅ ក្នុងតេភូមិកធម៌ទាំងអស់ លះបង់តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះព្រោះ អស់តណ្ហា បើតថាគតត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត។

(បិ. ៥២ ទំ. ៩៦)

៣៥៤.២១ សព្ពទានំ ធម្មទានំ ជិនាតិ, សព្ពរសំ ធម្មរសោ ជិនាតិ;

សព្ពរតឹ ធម្មរតិ ជិនាតិ, តណ្ហក្ខយោ សព្ពទុក្ខំ ជិនាតិ។

ធម្មទានឈ្មះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្ដីត្រេកអរក្នុងធម៌ឈ្នះសេចក្ដីត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង។

(បិ. ៥២ ទំ. ៩៦)

៣៥៥.២២ ហនន្តិ ភោគា ទុម្មេធំ, នោ ច បារគវេសិនោ;

ភោគតណ្ហាយ ទុម្មេធោ, ហន្តិ អញ្ញេវ អត្តនំ។

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញ ប៉ុន្តែសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញ រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ។

(បិ. ៥២ ទំ. ៩៧)

៣៥៦.២៣ តិណទោសានិ ខេត្តានិ, រាគទោសា អយំ បជា;

តស្មា ហិ វីតរាគេសុ, ទិន្នំ ហោតិ មហប្ផលំ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទាន ដែលបុគ្គលឲ្យហើយ ដល់បុគ្គលមានរាគៈអស់ហើយរមែងជាទានមានផលច្រើន។

(បិ. ៥២ ទំ. ៩៧)

៣៥៧.២៤ តិណទោសានិ ខេត្តានិ, ទោសទោសា អយំ បជា;

តស្មា ហិ វីតទោសេសុ, ទិន្នំ ហោតិ មហប្ផលំ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន។

(បិ. ៥២ ទំ. ៩៧)

៣៥៨.២៥ **តិណទោសានិ ខេត្តានិ, មោហទោសា អយំ បជា;**

**តស្មា ហិ វីតមោហេសុ, ទិន្នំ ហោតិ មហប្ផលំ។**

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន។

(បិ. ៥២ ទំ. ៩៧)

៣៥៩.២៦ **តិណទោសានិ ខេត្តានិ, ឥច្ឆាទោសា អយំ បជា;**

**តស្មា ហិ វិគតិច្ឆេសុ, ទិន្នំ ហោតិ មហប្ផលំ។**

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីច្រណែនជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានសេចក្តីច្រណែនអស់ហើយ រមែងជាទានមានផលច្រើន។

(បិ. ៥២ ទំ. ៩៧)

ចប់តណ្ហាវគ្គ។

## ២៥. ភិក្ខុវគ្គ

៣៦០.១ **ចក្ខុនា សំវរោ សាធុ, សាធុ សោតេន សំវរោ;**

**ឃានេន សំវរោ សាធុ, សាធុ ជិវ្ហាយ សំវរោ។**

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ។

(បិ. ៥២ ទំ. ៩៨)

៣៦១.២ **កាយេន សំវរោ សាធុ, សាធុ វាចាយ សំវរោ;**

មនសា សំវរោ សាធុ, សាធុ សព្ពត្ថ សំវរោ;
សព្ពត្ថ សំវុតោ ភិក្ខុ, សព្ពទុក្ខា បមុច្ចតិ។

ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួង។

(បិ. ៥២ ទំ. ៩៨)

៣៦២.៣ ហត្ថសញ្ញតោ បាទសញ្ញតោ,
វាចាយសញ្ញតោ សញ្ញតុត្តមោ;
អជ្ឈត្តរតោ សមាហិតោ,
ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ។

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចំរើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាហេតុមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅជននោះថាភិក្ខុ។

(បិ. ៥២ ទំ. ៩៨)

៣៦៣.៤ យោ មុខសញ្ញតោ ភិក្ខុ, មន្តភាណី អនុទ្ធតោ;
អត្ថំ ធម្មញ្ច ទីបេតិ, មធុរំ តស្ស ភាសិតំ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សំដែងអត្ថផង ធម៌ផង បានភាសិតរបស់ភិក្ខុនោះទើបឈ្មោះថាពីរោះ។

(បិ. ៥២ ទំ. ៩៨)

៣៦៤.៥ ធម្មារាមោ ធម្មរតោ, ធម្មំ អនុវិចិន្តយំ;
ធម្មំ អនុស្សរំ ភិក្ខុ, សទ្ធម្មា ន បរិហាយតិ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ។

(បិ. ៥២ ទំ. ៩៨)

៣៦៥.៦ សលាភំ នាតិមញ្ញេយ្យ, នាញ្ញេសំ បិហយំ ចរេ;
អញ្ញេសំ បិហយំ ភិក្ខុ, សមាធឹ នាធិគច្ឆតិ។

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃរមែងមិនបានសមាធិឡើយ។

(បិ. ៥២ ទំ. ៩៩)

៣៦៦.៧ អប្បលាភោបិ ចេ ភិក្ខុ, សលាភំ នាតិមញ្ញតិ;
តំ វេ ទេវា បសំសន្តិ, សុទ្ធាជីវឹ អតន្ទិតំ។

បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតានិងមនុស្សទាំងឡាយតែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយបរិសុទ្ធិ ជាអ្នកមិនខ្ជិលច្រអូស។

(បិ. ៥២ ទំ. ៩៩)

៣៦៧.៨ សព្វសោ នាមរូបស្មឹ, យស្ស នត្ថិ មមាយិតំ;
អសតា ច ន សោចតិ, ស វេ ភិក្ខូតិ វុច្ចតិ។

បុគ្គលណាមិនមានសេចក្ដីប្រកាន់ក្នុងនាមនិងរូបជារបស់អញ ដោយប្រការទាំងពួងមួយទៀត បុគ្គលណា មិនសោកស្ដាយ ព្រោះនាមនិងរូបមិនមាន បុគ្គលនោះឯងតថាគតហៅថា ភិក្ខុ។

(បិ. ៥២ ទំ. ៩៩)

៣៦៨.៩ មេត្តាវិហារី យោ ភិក្ខុ, បសន្នោ ពុទ្ធសាសនេ;
អធិគច្ឆេ បទំ សន្តំ, សង្ខារូបសមំ សុខំ។

ភិក្ខុណានៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្ដីសុខ។

(បិ. ៥២ ទំ. ៩៩)

៣៦៩.១០ សិញ្ច ភិក្ខុ ឥមំ នាវំ, សិត្តា តេ លហុមេស្សតិ;
ឆេត្វា រាគញ្ច ទោសញ្ច, តតោ និព្វានមេហិសិ។

ម្នាលភិក្ខុ ចូរអ្នកស្តារទូកគឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពីនោះនឹងអាចដល់នូវព្រះព្រះនិព្វាន។

(បិ. ៥២ ទំ. ៩៩)

៣៧០.១១ បញ្ច ឆិន្ទេ បញ្ច ជហេ, បញ្ច ចុត្តរិ ភាវយេ;
បញ្ច សង្គាតិគោ ភិក្ខុ, ឱឃតិណ្ណោតិ វុច្ចតិ។

ភិក្ខុគាប់កាត់ ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចំរើនឥន្ទ្រិយ ៥ តទៅ ភិក្ខុអ្នកកន្លងកិលេសជាគ្រឿងចំកាត់ ៥ (រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន។

(បិ. ៥២ ទំ. ៩៩)

៣៧១.១២ ឈាយ ភិក្ខុ មា បមាទោ ,
មា តេ កាមគុណេ ភមស្សុ ចិត្តំ;
មា លោហគុឡំ គិលី បមត្តោ,
មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរជាអ្នកកុំប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះឡើយ។

(បិ. ៥២ ទំ. ១០០)

៣៧២.១៣ នត្ថិ ឈានំ អបញ្ញស្ស, បញ្ញា នត្ថិ អឈាយិនោ ;
យម្ហិ ឈានញ្ច បញ្ញា ច, ស វេ និព្វានសន្តិកេ។

ការពិនិត្យមិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យនិងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះព្រះនិព្វាន។

(បិ. ៥២ ទំ. ១០០)

៣៧៣.១៤ សុញ្ញាគារំ បវិដ្ឋស្ស, សន្តចិត្តស្ស ភិក្ខុនោ;
អមានុសី រតិ ហោតិ, សម្មា ធម្មំ វិបស្សតោ។

សេចក្តីត្រេកអរ ដែលមិនមានជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធមិដោយប្រពៃ។

(បិ. ៥២ ទំ. ១០០)

៣៧៤.១៥ យតោ យតោ សម្មសតិ, ខន្ធានំ ឧទយព្វយំ;
លភតី បីតិបាមោជ្ជំ, អមតំ តំ វិជានតំ។

ភិក្ខុពិចារណាការកើតឡើងនិងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិនិងបាមោជ្ជៈ បីតិនិងបាមោជ្ជៈនោះ ឈ្មោះថា ជាអមតធមិ របស់បណ្ឌិតអ្នកដឹងធមិទាំងឡាយ។

(បិ. ៥២ ទំ. ១០០)

៣៧៥.១៦ តត្រាយមាទិ ភវតិ, ឥធ បញ្ញស្ស ភិក្ខុនោ;
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ, បាតិមោក្ខេ ច សំវរោ។

គុណ៣ប្រការនេះ គឺការរក្សាឥន្ទ្រិយ១ សេចក្តីសន្តោស១ ការសង្រួមក្នុងបាតិមោក្ខ១ ជាខាងដើមនៃព្រះព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ។

(បិ. ៥២ ទំ. ១០០)

៣៧៦.១៧ មិត្តេ ភជស្សុ កល្យាណេ, សុទ្ធាជីវេ អតន្ទិតេ;
បដិសន្ថារវុត្យស្ស , អាចារកុសលោ សិយា;
តតោ បាមោជ្ជពហុលោ, ទុក្ខស្សន្តំ ករិស្សសិ។

ម្នាលភិក្ខុ អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធិ ជាអ្នកមិនខ្ជិលច្រអូស ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសន្ថារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជៈច្រើន នឹងធ្វើទីបំផុតទុក្ខបាន។

(បិ. ៥២ ទំ. ១០០)

៣៧៧.១៨ វស្សិកា វិយ បុប្ផានិ, មទ្ទវានិ [មជ្ជវានិ បមុញ្ចតិ;
ឯវំ រាគញ្ច ទោសញ្ច, វិប្បមុញ្ចេថ ភិក្ខវោ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជំរុះរាគៈ និងទោសៈចេញ ដូចម្លិះជំរុះផ្កាម្លិះទាំងឡាយ ដែលស្វិតហើយ ដូច្នោះ។

(បិ. ៥២ ទំ. ១០១)

៣៧៨.១៩ សន្តកាយោ សន្តវាចោ, សន្តមនោ សុសមាហិតោ ;
វន្តលោកាមិសោ ភិក្ខុ, ឧបសន្តោតិ វុច្ចតិ។

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសៈក្នុងលោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់។

(បិ. ៥២ ទំ. ១០១)

៣៧៩.២០ អត្តនា ចោទយត្តានំ, បដិមំសេ តមត្តនា ;
សោ អត្តគុត្តោ សតិមា, សុខំ ភិក្ខុ វិហាហិសិ។

អ្នកចូរដាស់តឿនខ្លួនឯងដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើមាន ស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ។

(បិ. ៥២ ទំ. ១០១)

៣៨០.២១ អត្តា ហិ អត្តនោ នាថោ, អត្តា ហិ អត្តនោ គតិ;
តស្មា សញ្ញមអត្តានំ , អស្សំ ភទ្រំវ វាណិជោ។

មែនពិតខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួន ដូចពាណិជរវាំងសេះដ៏ល្អ។

(បិ. ៥២ ទំ. ១០១)

៣៨១.២២ បាមោជ្ជពហុលោ ភិក្ខុ, បសន្នោ ពុទ្ធសាសនេ;

អជិតច្ចេ បទំ សន្តំ, សង្ខារូបសមំ សុខំ។

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងប់នូវសង្ខារ នាំមកនូវសេចក្តីសុខ។

(បិ. ៥២ ទំ. ១០១)

៣៨២.២៣ យោ ហវេ ទហរោ ភិក្ខុ, យុញ្ជតិ ពុទ្ធសាសនេ;
សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។

ភិក្ខុណានៅកម្លោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញ៉ាំងលោកនេះ ឲ្យភ្លឺ ស្វាងបាន ដូចព្រះចន្ទដែលរះផុតអំពីពពក។

(បិ. ៥២ ទំ. ១០១)

ចប់ភិក្ខុវគ្គ។

## ២៦. ព្រាហ្មណវគ្គ

៣៨៣.១ ឆិន្ទ សោតំ បរក្កម្ម, កាមេ បនុទ ព្រាហ្មណ;
សង្ខារានំ ខយំ ញត្វា, អកតញ្ញូសិ ព្រាហ្មណ។

ម្នាលព្រាហ្មណ៍ អ្នកចូរខំប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថាជាអ្នកដឹងព្រះ ព្រះនិព្វានដែលបច្ច័យតាក់តែងមិនបាន។

(បិ. ៥២ ទំ. ១០២)

៣៨៤.២ យទា ទ្វយេសុ ធម្មេសុ, បារគូ ហោតិ ព្រាហ្មណោ;
អថស្ស សព្វេ សំយោគា, អត្ថំ គច្ឆន្តិ ជានតោ។

កាលណាព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការគឺ សមថធម៌និងវិបស្សនាធម៌ ក្នុង កាលណោះ កិលេសគ្រឿងប្រកបសត្វទុកទាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវ ការតាំងនៅមិនបាន។

(បិ. ៥២ ទំ. ១០២)

៣៨៥.៣ យស្ស បារំ អបារំ វា, បារាបារំ ន វិជ្ជតិ;
វីតទ្ទរំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

ត្រើយក្តី ទីមិនមែនត្រើយក្តី ត្រើយនិងទីមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០២)

៣៨៦.៤ ឈាយឹ វិរជមាសីនំ, កតកិច្ចមនាសវំ;
ឧត្តមត្ថមនុប្បត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលអ្នកចំរើនឈាន មានធូលីគឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ដោយលំដាប់ហើយនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០២)

៣៨៧.៥ ទិវា តបតិ អាទិច្ចោ, រត្តិមាភាតិ ចន្ទិមា;
សន្នទ្ធោ ខត្តិយោ តបតិ, ឈាយី តបតិ ព្រាហ្មណោ;
អថ សព្ពមហោរត្តឹ , ពុទ្ធោ តបតិ តេជសា។

ព្រះអាទិត្យរុងរឿង ក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង សមណព្រាហ្មណ៍អ្នកមានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធរមែងរុងរឿងដោយតេជៈរហូតថ្ងៃនិងយប់ទាំងអស់។

(បិ. ៥២ ទំ. ១០៣)

៣៨៨.៦ ពាហិតបាបោតិ ព្រាហ្មណោ, សមចរិយា សមណោតិ វុច្ចតិ;
បព្ពាជយមត្តនោ មលំ, តស្មា បព្ពជិតោតិ វុច្ចតិ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថាព្រាហ្មណ៍ អ្នកដែលតថាគតហៅថាសមណៈ ព្រោះការប្រព្រឹត្តិរម្ងាប់ អ្នកដែលដេញមន្ទិលនៃខ្លួន ហេតុនោះទើបតថាគតហៅថាបព្ពជិត។

(បិ. ៥២ ទំ. ១០៣)

៣៨៩.៧ ន ព្រាហ្មណស្ស បហរេយ្យ, នាស្ស មុញ្ចេថ ព្រាហ្មណោ;
ធី ព្រហ្មណស្ស ហន្តារំ, តតោ ធិ យស្ស មុញ្ចតិ។

ព្រាហ្មណ៍មិនគប្បីប្រហារប្រហារព្រាហ្មណ៍ទេ ព្រាហ្មណ៍មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍ ដែលប្រហារព្រហ្មណ៍ ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះទៅទៀត។

(បិ. ៥២ ទំ. ១០៣)

៣៩០.៨ ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ,
យទា និសេធោ មនសោ បិយេហិ;
យតោ យតោ ហឹសមនោ និវត្តតិ,
តតោ តតោ សម្មតិមេវ ទុក្ខំ។

ការហាមឃាត់ចិត្ត ចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ងាកចេញចាកវត្ថុណា ៗ សេចក្ដីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន។

(បិ. ៥២ ទំ. ១០៣)

៣៩១.៩ យស្ស កាយេន វាចាយ, មនសា នត្ថិ ទុក្កដំ;
សំវុតំ តីហិ ឋានេហិ, តមហំ ព្រូមិ ព្រាហ្មណំ។

អំពើអាក្រក់ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្ត របស់បុគ្គលណា មិនមានទេ តថាគតហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង៣នោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៤)

៣៩២.១០ យម្ហា ធម្មំ វិជានេយ្យ, សម្មាសម្ពុទ្ធទេសិតំ;
សក្កច្ចំ តំ នមស្សេយ្យ, អគ្គិហុត្តំវ ព្រាហ្មណោ។

បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ អំពីសំណាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើងដូច្នោះដែរ។

(បិ. ៥២ ទំ. ១០៤)

៣៩៣.១១ ន ជដាហិ ន គោត្តេន, ន ជច្ចា ហោតិ ព្រាហ្មណោ;
យម្ហិ សច្ចញ្ច ធម្មោ ច, សោ សុចី សោ ច ព្រាហ្មណោ។

បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះផ្នួងសក់ក៏មិនមែន ព្រោះគោត្រក៏មិនមែន ព្រោះជាតិក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ផង។

(បិ. ៥២ ទំ. ១០៤)

៣៩៤.១២ កិន្តេ ជដាហិ ទុម្មេធ, កិន្តេ អជិនសាដិយា;
អព្ភន្តរន្តេ គហនំ, ពាហិរំ បរិមជ្ជសិ។

នៃអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការទុកផ្នួងសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្តានខាងក្នុងរបស់ខ្លួន សឹងសាំញុំាដោយរាគាទិក្កិលេស អ្នកឈ្មោះថាដុសខាត់តែកាយខាងក្រៅទេ។

(បិ. ៥២ ទំ. ១០៤)

៣៩៥.១៣ បំសុកូលធរំ ជន្តុំ, កិសន្ធមនិសន្ថតំ;
ឯកំ វនស្មឹ ឈាយន្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលអ្នកទ្រទ្រង់សំពត់បំសុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯង ចំរើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៤)

៣៩៦.១៤ ន ចាហំ ព្រាហ្មណំ ព្រូមិ, យោនិជំ មត្តិសម្ភវំ;
ភោវាទិ នាម សោ ហោតិ, សចេ ហោតិ សកិញ្ចនោ;
អកិញ្ចនំ អនាទានំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតនឹងហៅអ្នកកើត អំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណ៍ជាមាតា ថាជាព្រាហ្មណ៍ក៏ទេ បុគ្គលនោះគ្រាន់តែបាននាមថា ភោវាទី ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿង កង្វល់នៅឡើយ តថាគតហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់អ្នកមិនមានសេចក្តីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៥)

៣៩៧.១៥ សព្វសំយោជនំ ឆេត្វា, យោ វេ ន បរិតស្សតិ;
សង្គាតិគំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណា កាត់សញ្ញោជនៈទាំងអស់បាន មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងចំពាក់ អ្នករួចស្រឡះចាកកិលេសថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៥)

៣៩៨.១៦ ឆេត្វា នន្ទឹ វរត្តញ្ច, សន្ទានំ សហនុក្កមំ;
ឧក្ខិត្តបលិឃំ ពុទ្ធំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលដែលកាត់សេចក្តីក្រោធ ដូចព្ជូរផង កាត់តណ្ហាដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទឹក ព្រមទាំងអនុស័យ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសរសរខឿនដកចោលហើយ អ្នកត្រាស់ដឹងសច្ចៈ៤ នោះឯង ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៥)

៣៩៩.១៧ អក្កោសំ វធពន្ធញ្ច, អទុដ្ឋោ យោ តិតិក្ខតិ;
ខន្តីពលំ ពលានីកំ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាមិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀននិងការចងផងបាន ទើបតថាគតហៅបុគ្គលដែលមានខន្តិជាពលៈ មានខន្តិជាវរេហ៍ពលនោះផង ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៥)

៤០០.១៨ អក្កោធនំ វតវន្តំ, សីលវន្តំ អនុស្សទំ;
ទន្តំ អន្តិមសារីរំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្ដីក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល មិនមានតណ្ហាគ្រោះឯប៉ោងចិត្ត មានឥន្ទ្រីយទូន្មានហើយ មានសរីរៈឋិតនៅ ក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៦)

៤០១.១៩ វារិ បោក្ខរបត្តេវ, អារគ្គេរិវ សាសបោ;
យោ ន លិម្បតិ កាមេសុ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាមានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៦)

៤០២.២០ យោ ទុក្ខស្ស បជានាតិ, ឥធេវ ខយមត្តនោ;
បន្នភារំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខរបស់ខ្លួន តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារដាក់ចុះហើយ ដែលរួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៦)

៤០៣.២១ គម្ភីរបញ្ញំ មេធាវឹ, មគ្គាមគ្គស្ស កោវិទំ;
ឧត្តមត្ថមនុប្បត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទំលាយកិលេស អ្នកឈ្លាស ក្នុងផ្លូវនិងមិនមែនផ្លូវ បានសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៦)

៤០៤.២២ អសំសដ្ឋំ គហដ្ឋេហិ, អនាគារេហិ ចូភយំ;
អនោកសារិមប្បិច្ឆំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលដែលមិនច្រឡំ ដោយជនទាំងឡាយពីរពួក គឺគ្រហស្ថ១ បព្ពជិត១ ជាអ្នកត្រាច់ទៅដោយមិនមានសេចក្តីអាល័យ មានសេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៦)

៤០៥.២៣ និធាយ ទណ្ឌំ ភូតេសុ, តសេសុ ថាវរេសុ ច;

យោ ន ហន្តិ ន ឃាតេតិ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី ដែលមាំមួន គឺមិនមានតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៧)

៤០៦.២៤ អវិរុទ្ធំ វិរុទ្ធេសុ, អត្តទណ្ឌេសុ និព្វុតំ;

សាទានេសុ អនាទានំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករំលត់ចំពោះពួកជនដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ ចំពោះពួកជនដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៧)

៤០៧.២៥ យស្ស រាគោ ច ទោសោ ច, មានោ មក្ខោ ច ចាតិតោ;

សាសបោរិវ អារគ្គា, តមហំ ព្រូមិ ព្រាហ្មណំ។

រាគៈ ទោសៈ មានៈ និងមក្ខៈ ដែលបុគ្គលណា បានជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៧)

៤០៨.២៦ អកក្កសំ វិញ្ញាបនិំ, គិរំ សច្ចមុទីរយេ;

យាយ នាភិសជេ កញ្ចិ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្ដីបានជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណាឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៧)

៤០៩.២៧ យោធ ទីឃំ វ រស្សំ វា, អណុំ ថូលំ សុភាសុភំ;
លោកេ អទិន្នំ នាទិយតិ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណា មិនកាន់យករបស់វែងឬខ្លី តូចឬធំ ល្អឬអាក្រក់ ដែលគេមិនបានឲ្យហើយក្នុងលោកនេះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៧)

៤១០.២៨ អាសា យស្ស ន វិជ្ជន្តិ, អស្មិំ លោកេ បរម្ហិ ច;
និរាសយំ វិសំយុត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

អ្នកណា មិនមានសេចក្ដីប្រាថ្នាក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្ដីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៧)

៤១១.២៩ យស្សាលយា ន វិជ្ជន្តិ, អញ្ញាយ អកថំកថី;
អមតោគធមនុប្បត្តំ, តមហំ ព្រូមិ ព្រាហ្មណំ។

អ្នកណាមិនមានសេចក្ដីអាល័យគឺតណ្ហា មិនមានសេចក្ដីសង្ស័យក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមិនមានចិត្តចុះស៊ប់កាន់ព្រះព្រះនិព្វាន ដែលមានព្រះអរហន្តដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៨)

៤១២.៣០ យោធ បុញ្ញញ្ច បាបញ្ច, ឧភោ សង្គមុបច្ចគា;
អសោកំ វិរជំ សុទ្ធំ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាក្នុងលោកនេះ លះបង់បុណ្យនិងបាបទាំងពីរ និងកិលេសជាគ្រឿងចំពាក់ចេញហើយ តថាគតហៅបុគ្គលនោះដែលជាអ្នកមិនមានសេចក្តីសោក មានធូលីគឺកិលេសអស់ ហើយជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៨)

៤១៣.៣១ ចន្ទំវ វិមលំ សុទ្ធំ, វិប្បសន្នមនាវិលំ;
នន្ទីភវបរិក្ខីណំ, តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទ្រប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់សេចក្តីត្រេតអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៨)

៤១៤.៣២ យោមំ បលិបថំ ទុគ្គំ, សំសារំ មោហមច្ចគា;
តិណ្ណោ បារគតោ ឈាយី, អនេជោ អកថំកថី;
អនុបាទាយ និព្វុតោ, តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាកន្លងផ្លូវវាងគឺរាគៈ និងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នកឆ្លងកន្លងអន្លង់ទាំង៤បានដល់ត្រើយគឺព្រះព្រះនិព្វាន ជាអ្នកមាន ឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៨)

៤១៥.៣៣ យោធ កាមេ បហន្ត្វាន, អនាគារោ បរិព្ពជេ;
កាមភវបរិក្ខីណំ, តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាម បាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៩)

៤១៦.៣៤ យោធ តណ្ហំ បហន្ត្វាន, អនាគារោ បរិព្ពជេ;

តណ្ហាភវបរិក្ខីណំ ,                តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាក តណ្ហាបាន តថាគតហៅបុគ្គលដែលអស់តណ្ហា និងភពហើយនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៩)

៤១៧.៣៥ ហិត្វា មានុសកំ យោគំ,                ទិព្ពំ យោគំ ឧបច្ចគា;

សព្ពយោគវិសំយុត្តំ,                តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាលះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្សកន្លងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គល ដែលផុតស្រឡះ ចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៩)

៤១៨.៣៦ ហិត្វា រតិញ្ច អរតិញ្ច,                សីតិភូតំ និរូបធឹ;

សព្ពលោកាភិភុំ វីរំ,                តមហំ ព្រូមិ ព្រាហ្មណំ។

តថាគតហៅបុគ្គលដែលលះបង់សេចក្ដីត្រេកអរក្នុងកាមគុណនិងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់មិនមានឧបក្កិលេស គ្របសង្កត់លោកទាំងពួង មានសេចក្ដីព្យាយាមនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៩)

៤១៩.៣៧ ចុតឹ យោ វេទិ សត្តានំ,                ឧបបត្តិញ្ច សព្ពសោ;

អសត្តំ សុគតំ ពុទ្ធំ,                តមហំ ព្រូមិ ព្រាហ្មណំ។

បុគ្គលណាដឹងច្បាស់ចុតិនិងបដិសន្ធិរបស់ពួងសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់ក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្ដីប្រតិបត្តិ អ្នកត្រាស់ដឹងនូវ សច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១០៩)

៤២០.៣៨ យស្ស គតឹ ន ជានន្តិ,                ទេវា គន្ធព្ពមានុសា;

**ខីណាសវំ អរហន្តំ,　　　　តមហំ ព្រូមិ ព្រាហ្មណំ។**

ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិ របស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១១០)

៤២១.៣៩　**យស្ស បុរេ ច បច្ឆា ច,　　　　មជ្ឈេ ច នត្ថិ កិញ្ចនំ;**
**អកិញ្ចនំ អនាទានំ,　　　　តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណា មិនមានសេចក្ដីកង្វល់ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្ដាលផង តថាគតហៅបុគ្គលដែលជាអ្នកមិនមានសេចក្ដីកង្វល់ មិនមានសេចក្ដីប្រកាន់នោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១១០)

៤២២.៤០　**ឧសភំ បវរំ វីរំ,　　　　មហេសិំ វិជិតាវិនំ;**
**អនេជំ ន្ហាតកំ ពុទ្ធំ,　　　　តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំឈ្នះមារ មិនមានកិលេស ជាគ្រឿងញាប់ញ័រ ងូតលាងកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១១០)

៤២៣.៤១　**បុព្ពេនិវាសំ យោ វេទិ,　　　　សគ្គាបាយញ្ច បស្សតិ,**
**អថោ ជាតិក្ខយំ បត្តោ,　　　　អភិញ្ញាវោសិតោ មុនិ;**
**សព្ពវោសិតវោសានំ,　　　　តមហំ ព្រូមិ ព្រាហ្មណំ។**

បុគ្គលណាដឹងច្បាស់ខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់អាស្រ័យក្នុងកាលមុនផង ឃើញច្បាស់នូវឋានសួគ៌ និងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញស្រេចកិច្ច ហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គល ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ចប់សព្វគ្រប់ហើយ នោះ ថាជាព្រាហ្មណ៍។

(បិ. ៥២ ទំ. ១១០)

ចប់ព្រាហ្មណវគ្គ។
ចប់ធម្មបទគាថា។